ម៉ូឌុលទី ២

# សុខភាព

## កញ្ចប់សេវាសំខាន់ៗសម្រាប់
## ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា
## គោលការណ៍ណែនាំស្តីពីសមាសធាតុស្នូល និងគុណភាព

# ម៉ូឌុលទី ២

## សេវាសុខភាព

កញ្ចប់សេវាសំខាន់ៗមាន ៥ ម៉ូឌុល ៖

| **ម៉ូឌុលទី ១**<br>**ខ្លឹមសារសង្ខេប និង សេចក្តីផ្តើម** | **ម៉ូឌុលទី ២**<br>**សុខភាព** | **ម៉ូឌុលទី ៣**<br>**យុត្តិធម៌ និងការរក្សាសណ្តាប់ធ្នាប់** | **ម៉ូឌុលទី ៤**<br>**សេវាសង្គម** | **ម៉ូឌុលទី ៥**<br>**ការសម្រប សម្រួល និងការគ្រប់គ្រងការងារសម្របសម្រួល** |
|---|---|---|---|---|
| **ជំពូក ១**<br>**សេចក្តីផ្តើមស្តីពីកញ្ចប់សេវាសំខាន់ៗ**<br>១.១ សេចក្តីផ្តើម<br>១.២ បរិបទ<br>១.៣ គោលបំណង និងវិសាលភាព<br>១.៤ ភាសា និងពាក្យបច្ចេកទេស | **ជំពូក ១**<br>**សេចក្តីផ្តើមស្តីពីសេវាសុខភាពសំខាន់ៗ**<br>១.១ សេចក្តីផ្តើម<br>១.២ គោលបំណង និងវិសាលភាព<br>១.៣ ភាសា និងពាក្យបច្ចេកទេស | **ជំពូក ១**<br>**សេចក្តីផ្តើមស្តីពីសេវាយុត្តិធម៌ និងការរក្សាសណ្តាប់ធ្នាប់សំខាន់ៗ**<br>១.១ សេចក្តីផ្តើម<br>១.២ គោលបំណង និងវិសាលភាព<br>១.៣ ភាសា និងពាក្យបច្ចេកទេស | **ជំពូក ១**<br>**សេចក្តីផ្តើមស្តីពីសេវាសង្គម សំខាន់ៗ**<br>១.១ សេចក្តីផ្តើម<br>១.២ គោលបំណង និងវិសាលភាព<br>១.៣ ភាសា និងពាក្យបច្ចេកទេស | **ជំពូក ១**<br>**សេចក្តីផ្តើមស្តីពី សកម្មភាព សម្របសម្រួល និង អភិបាលកិច្ចសំខាន់ៗ**<br>១.១ សេចក្តីផ្តើម<br>១.២ គោលបំណង និងវិសាលភាព<br>១.៣ ភាសា និងពាក្យបច្ចេកទេស |
| **ជំពូក ២**<br>**គោលការណ៍ទូទៅ លក្ខណៈ និង សមាសធាតុគ្រឹះ**<br>២.១ គោលការណ៍<br>២.២ លក្ខណៈទូទៅនៃសេវាសំខាន់ៗដែលមានគុណភាព<br>២.៣ សមាសធាតុគ្រឹះ | **ជំពូក ២**<br>**ក្របខណ្ឌសម្រាប់កញ្ចប់សេវាសំខាន់ៗ**<br>២.១ ក្របខណ្ឌទូទៅ<br>២.២ លក្ខណៈពិសេសនៃក្របខណ្ឌសម្រាប់សេវាសុខភាពសំខាន់ៗ | **ជំពូក ២**<br>**ក្របខណ្ឌសម្រាប់កញ្ចប់សេវាសំខាន់ៗ**<br>២.១ ក្របខណ្ឌទូទៅ<br>២.២ លក្ខណៈពិសេសនៃក្របខណ្ឌសម្រាប់សេវាយុត្តិធម៌ និងការរក្សាសណ្តាប់ធ្នាប់សំខាន់ៗ | **ជំពូក ២**<br>**ក្របខណ្ឌសម្រាប់កញ្ចប់សេវាសំខាន់ៗ**<br>២.១ ក្របខណ្ឌទូទៅ<br>២.២ លក្ខណៈពិសេសនៃក្របខណ្ឌសម្រាប់សេវាសង្គមសំខាន់ៗ | **ជំពូក ២**<br>**ក្របខណ្ឌសម្រាប់កញ្ចប់សេវាសំខាន់ៗ**<br>២.១ ក្របខណ្ឌទូទៅ |
| **ជំពូក ៣**<br>**របៀបប្រើប្រាស់ឧបករណ៍នេះ**<br>៣.១ ក្របខណ្ឌគោលការណ៍ណែនាំស្តីពីសេវាសំខាន់ៗ | **ជំពូក ៣**<br>**គោលការណ៍ណែនាំសម្រាប់សេវាសុខភាពសំខាន់ៗ** | **ជំពូក ៣**<br>**គោលការណ៍ណែនាំសម្រាប់សេវាយុត្តិធម៌ និងការរក្សាសណ្តាប់ធ្នាប់ សំខាន់ៗ** | **ជំពូក ៣**<br>**គោលការណ៍ណែនាំសម្រាប់សេវាសង្គមសំខាន់ៗ** | **ជំពូក ៣**<br>**គោលការណ៍ណែនាំសម្រាប់ សកម្មភាពសម្របសម្រួល និងអភិបាលកិច្ចសំខាន់ៗ** |
| **ជំពូក ៤**<br>**ឧបករណ៍ និងធនធាន** | **ជំពូក ៤**<br>**ឧបករណ៍ និងធនធាន** | **ជំពូក ៤**<br>**ឧបករណ៍ និងធនធាន** | **ជំពូក ៤**<br>**ឧបករណ៍ និងធនធាន** | **ជំពូក ៤**<br>**ឧបករណ៍ និងធនធាន** |

# សេចក្តីថ្លែងអំណរគុណ

**ការបង្កើតគោលការណ៍ណែនាំទាំងនេះអាចសម្រេចទៅបាន ដោយមានការចូលរួមចំណែកពីភាគីជាច្រើន ៖**

ភាពអង់អាចរបស់ស្ត្រីជាច្រើនដែលប្រឈមនឹងអំពើហិង្សា និងលាតត្រដាងពីបទពិសោធន៍របស់ខ្លួន ព្រមទាំងសកម្មជន ជាពិសេសសកម្មជនមកពីអង្គការស្ត្រីនៅទូទាំងសកលលោក ដែលបានតស៊ូមតិឲ្យមានការផ្តល់សេវាសមស្រប និងការគាំទ្រដល់ស្ត្រីដែលប្រឈមនឹងអំពើហិង្សា។

កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលដែលកំពុងចាត់វិធានការ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី តាមរយៈកំណែទម្រង់ច្បាប់ គំនិតផ្តួចផ្តើមគោលនយោបាយ និងការអនុវត្តកម្មវិធីទប់ស្កាត់ និងឆ្លើយតប។

ម្ចាស់ជំនួយសំខាន់ៗសម្រាប់កម្មវិធីរួមរបស់សហប្រជាជាតិ ស្តីពីសេវាសំខាន់ៗសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ៖ រដ្ឋាភិបាលប្រទេសអូស្ត្រាលី និងអេស្ប៉ាញ។

អ្នកជំនាញអន្តរវិស័យ អ្នកស្រាវជ្រាវ តំណាងរដ្ឋាភិបាលដែលបានចូលរួម និងចែករំលែកក្នុងការពិគ្រោះយោបល់បច្ចេកទេសជាសកល ស្តីពីការឆ្លើយតបរបស់វិស័យសុខាភិបាលទៅនឹងអំពើហិង្សាលើស្ត្រី ដែលបានចូលរួមចំណែកដល់ការតាក់តែងគោលការណ៍ណែនាំនេះព្រមទាំង ឧបករណ៍ និងការណែនាំជាបន្តបន្ទាប់ទៀត (ខ្លឹមសារលម្អិតស្តីពីអ្នកចូលរួមមានក្នុងគេហទំព័រ ៖ www.end_vawnow.org។ សូមចុចលើពាក្យ សេវាសំខាន់ៗ-Essential Services)។

ការប្តេជ្ញាចិត្តជាបន្តបន្ទាប់របស់ប្រព័ន្ធសហប្រជាជាតិក្នុងការបង្កើតកម្មវិធី និងវិធានការឆ្លើយតបនឹងអំពើហិង្សាលើស្ត្រី។ ទីភ្នាក់ងារសហប្រជាជាតិដែលបានចូលរួមក្នុងការគាំទ្រការកែសម្រួល និង/ឬ ការបង្កើតគោលការណ៍ណែនាំទាំងនេះ បានចំណាយពេលវេលា និងផ្តល់ចំណេះដឹងរបស់ពួកគេដើម្បីធានាថា យើងបន្តបង្កើនការផ្តល់សេវាដល់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា។ តំណាងទីភ្នាក់ងារសូមថ្លែងអំណរគុណចំពោះការប្តេជ្ញាចិត្ត និងការផ្តល់មតិយោបល់របស់ ៖ Tania Farha និង Riet Groenen (UN Women), Upala Devi និង Luis Mora (UNFPA), Claudia Garcia Moreno និង Avni Amin (WHO)។ យើងសូមថ្លែងអំណរគុណជាពិសេសចំពោះកិច្ចសហការដ៏យូរអង្វែងរបស់អង្គការសុខភាពពិភពលោក (WHO) ដែលបានជួយដល់ការតាក់តែងការណែនាំជាច្រើនស្តីពីការលើកកម្ពស់ការឆ្លើយតបរបស់វិស័យសុខាភិបាលទៅនឹងស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា។ សកម្មភាពនេះបានផ្តល់ព័ត៌មានសម្រាប់ការបង្កើតម៉ូឌុលនេះឡើង។

ទីប្រឹក្សាដែលជួយដល់ការតាក់តែង និង/ឬ កែតម្រូវគោលការណ៍ណែនាំទាំងនេះ គឺសាស្ត្រាចារ្យ Jane Koziol-McLain, អ្នកស្រី Sarah Louise Johnson និងលោក Ward Everett Rinehart។

## មាតិកា


**ជំពូក ១ ៖ ការណែនាំពីសេវាសុខភាពសំខាន់ៗ ............ 6**

១.១ សេចក្តីផ្តើម ............ 6

១.២ គោលបំណង និងវិសាលភាព ............ 7

១.៣ ភាសា និងពាក្យបច្ចេកទេស ............ 9

**ជំពូក ២ ៖ ក្របខណ្ឌសម្រាប់កញ្ចប់សេវាសំខាន់ៗ. ............ 13**

២.១ ក្របខណ្ឌទូទៅ............ 13

២.២ លក្ខណៈពិសេសនៃក្របខណ្ឌសេវាសុខភាពសំខាន់ៗ ............ 15

**ជំពូក ៣ ៖ គោលការណ៍ណែនាំសម្រាប់សេវាសុខភាពសំខាន់ៗ ............ 17**

**ជំពូក ៤ ៖ ឧបករណ៍ និងធនធាន ............ 26**

# ជំពូក ១ ៖

# ការណែនាំពីសេវាសុខភាពសំខាន់ៗ

## ១.១ សេចក្ដីផ្ដើម

ការណែនាំសម្រាប់**សេវាសុខភាពសំខាន់ៗ**នេះផ្អែកលើគោលការណ៍ណែនាំផ្នែកគ្លីនិក និងគោលនយោបាយរបស់អង្គការសុខភាពពិភពលោក (WHO) *ស្ដីពីការឆ្លើយតបនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទលើស្ត្រី*[1] ក្នុងការអនុលោមតាមអាណត្តិរបស់អង្គការសុខភាពពិភពលោកដើម្បីបង្កើតស្តង់ដាក្នុងប្រព័ន្ធសុខាភិបាល។ គោលការណ៍ណែនាំផ្អែកតាមភស្តុតាងទាំងនេះត្រូវបានបង្កើតឡើង ដោយអនុលោមតាមដំណើរការបង្កើតគោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោកដែលរួមបញ្ចូល ៖ ការទាញយកមកវិញនូវភស្តុតាងបច្ចុប្បន្នភាព តាមរយៈការពិនិត្យឡើងវិញ ការវាយតម្លៃ និងការសំយោគភស្តុតាងជាប្រព័ន្ធ និងការផ្ដល់អនុសាសន៍ដោយទទួលបានមតិយោបល់ពីអ្នកជំនាញជាច្រើន (ក្រុមតាក់តែងគោលការណ៍ណែនាំ) និងការពិនិត្យគ្នាទៅវិញទៅមកដោយក្រុមអ្នកជំនាញមួយផ្សេងទៀត។ ពួកគេបានផ្ដល់ការណ៍ណែនាំផ្អែកតាមភស្តុតាងសម្រាប់ការរៀបចំអនុវត្ត និងពិនិត្យឡើងវិញលើគុណភាព ការឆ្លើយតបនៃវិស័យសុខាភិបាលដែលផ្ដោតលើស្ត្រី ប្រឈមនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និង អំពើហិង្សាផ្លូវភេទ។ គោលការណ៍ណែនាំនេះ ក៏អាចត្រូវបាន ប្រើប្រាស់ផងដែរសម្រាប់ទម្រង់ ផ្សេងទៀតនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រលើស្ត្រី និងក្មេងស្រី ជាពិសេសក្មេងស្រីដែលអាចប្រើប្រាស់សេវាសំខាន់ៗដែលផ្ដល់ឲ្យស្ត្រី ។ គោលការណ៍ណែនាំទាំងនេះត្រូវបានបង្កើតឡើង ដោយផ្ដោតលើប្រទេសមានប្រាក់ចំណូលទាបរហូតដល់ប្រទេសមានប្រាក់ចំណូលមធ្យមក្នុងមជ្ឈដ្ឋានថេរមួយ ប៉ុន្តែវាក៏អាចអនុវត្តក្នុងប្រទេសមានប្រាក់ចំណូលខ្ពស់បានដែរ។

ផ្អែកលើគោលការណ៍ណែនាំទាំងនេះ អង្គការ WHO, UNFPA និង UN Women បានបង្កើតសៀវភៅណែនាំគ្លីនិកស្ដីពីការថែទាំសុខភាពសម្រាប់ស្ត្រី *ដែលប្រឈមនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា ឬអំពើហិង្សាផ្លូវភេទ*[2] ។ នេះជាសៀវភៅណែនាំ "ការអនុវត្ត" សម្រាប់អ្នកផ្ដល់សេវាសុខភាព។ វារួមបញ្ចូលឧបករណ៍ជំនួយការងារ គន្លឹះ និងអនុសាសន៍ជាក់ស្ដែង។ អនុសាសន៍ទាំងនេះបង្កើតបានជាមូលដ្ឋានសម្រាប់ម៉ូឌុលស្ដីពីសេវាសុខភាពសំខាន់ៗ ដែលជាផ្នែកនៃកញ្ចប់សេវាសំខាន់ៗសំដៅផ្ដល់លទ្ធភាពធំធេងដល់ស្ត្រី និងក្មេងស្រីទាំងអស់ដែលប្រឈមនឹងអំពើហិង្សទាក់ទងនឹងយេនឌ័រ ឲ្យទទួលបានសេវាចម្រុះវិស័យសំខាន់ៗដែលមានគុណភាព និងការសម្របសម្រួល។ ដូច្នេះ ម៉ូឌុលនេះគួរត្រូវបានអានរួមគ្នានឹងឯកសារទាំងពីរខាងលើ។

1 អង្គការសុខភាពពិភពលោក, ការឆ្លើយតបនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទលើស្ត្រី ៖ គោលការណ៍ណែនាំ ផ្នែកគ្លីនិក និងគោលនយោបាយរបស់អង្គការសុខភាពពិភពលោក (WHO), ទីក្រុងហ្សឺណែវ ប្រទេសស្វីស ៖ អង្គការសុខភាពពិភពលោក ឆ្នាំ ២០១៣។

2 អង្គការ WHO, UNFPA និង UN Women ៖ ការថែទាំសុខភាពសម្រាប់ស្ត្រីដែលប្រឈមនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា ឬអំពើហិង្សាផ្លូវភេទ, សៀវភៅណែនាំគ្លីនិក ទីក្រុងហ្សឺណែវ ៖ WHO (WHO/RHR/14.26)។

**កញ្ចប់សេវាសំខាន់ៗ** ឆ្លុះបញ្ចាំងពីសមាសធាតុសំខាន់ៗនៃការឆ្លើយតបចម្រុះវិស័យដោយមានការសម្របសម្រួលសម្រាប់ស្ត្រី និងក្មេងស្រីដែលប្រឈមនឹងអំពើហិង្សា ដូចជាគោលការណ៍ណែនាំសម្រាប់សេវាយុត្តិធម៌ និងការរក្សាសណ្តាប់ធ្នាប់ គោលការណ៍ណែនាំសម្រាប់សេវាសង្គម គោលការណ៍ណែនាំស្តីអំពីការសម្របសម្រួល និងការគ្រប់គ្រងការងារសម្របសម្រួល និងគោលការណ៍ណែនាំសម្រាប់សេវាសុខភាព។

ម៉ូឌុលស្តីពីសេវាសុខភាពសំខាន់ៗនេះគួរត្រូវបានអានរួមគ្នានឹងម៉ូឌុលទី ១៖ ខ្លឹមសារសង្ខេប និងសេចក្តីផ្តើម ដែលបានកំណត់គោលការណ៍ លក្ខណៈទូទៅ និងសមាសធាតុគ្រឹះដែលអនុវត្តលើសេវាសំខាន់ៗទាំងអស់។ លើសពីនេះ ម៉ូឌុលនេះបំពេញបន្ថែមឲ្យគោលការណ៍ណែនាំសម្រាប់សេវាយុត្តិធម៌ និងការរក្សាសណ្តាប់ធ្នាប់ (ម៉ូឌុលទី ៣) សេវាសង្គម (ម៉ូឌុលទី ៤) និងការសម្រប សម្រួល និងការគ្រប់គ្រងការងារសម្របសម្រួល (ម៉ូឌុលទី ៥)។

## ១.២ គោលបំណង និងវិសាលភាព

ការឆ្លើយតបនៃសេវាសុខភាពដែលមានគុណភាពទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី មិនត្រឹមតែមានសារៈសំខាន់បំផុតក្នុងការធានាថា ជនរងគ្រោះមានលទ្ធភាពទទួលបានស្តង់ដាសេវាសុខភាពខ្ពស់បំផុតដែលគួរទទួលបាននោះទេ ប៉ុន្តែវាក៏មានសារៈសំខាន់ផងដែរសម្រាប់អ្នកផ្តល់ការថែទាំសុខភាព (ដូចជា គិលានុបដ្ឋាក ឆ្មប គ្រូពេទ្យ។ល។) ព្រោះថា ពួកគេគឺជាអ្នកជំនាញដំបូងដែលមានទំនាក់ទំនងជាមួយស្ត្រីដែលប្រឈមនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា ឬអំពើហិង្សាផ្លូវភេទ[3] ។ ជាញឹកញាប់ ស្ត្រី និងក្មេងស្រីស្វែងរកសេវាសុខភាពដើម្បីព្យាបាលរបួស ទោះបីជាពួកគាត់មិនបង្ហាញករណីពាក់ព័ន្ធនឹងការរំលោភបំពាន ឬអំពើហិង្សាក៏ដោយ។ ការសិក្សាបានបង្ហាញថា ស្ត្រីដែលរងការរំលោភបំពានប្រើប្រាស់សេវាថែទាំសុខភាពច្រើនជាងស្ត្រីធម្មតា[4] ។ ក្រៅពីនេះ ស្ត្រីចាត់ទុកអ្នកផ្តល់សេវាថែទាំសុខភាពថាជាអ្នកជំនាញដែលពួកគាត់ទុកចិត្តបំផុតក្នុងការបង្ហាញករណីរំលោភបំពាន។ ដើម្បីឆ្លើយតបនឹងតម្រូវការ និងបទពិសោធន៍ចម្រុះរបស់ស្ត្រី ម៉ូឌុលនេះលើកឡើងពីផលវិបាកសុខភាពទាំងអស់ ដូចជា ផលវិបាកសុខភាពបន្តពូជ ផ្លូវភេទ ផ្លូវចិត្ត និងផ្លូវកាយដែលបណ្តាលមកពី អំពើហិង្សាលើស្ត្រី។ ក្នុងការអំពាវនាវឲ្យមានសេចក្តីសន្និដ្ឋានរួមក្នុងកិច្ចប្រជុំលើកទី ៥៧ របស់គណៈកម្មការទទួលបន្ទុកស្ថានភាពស្ត្រី និងយោងតាមគោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោក ម៉ូឌុលនេះគ្របដណ្តប់លើអន្តរាគមន៍សុខភាពផ្សេងៗ ដូចជា (ការគាំទ្រជួរមុខ ការព្យាបាលរបួស និងការគាំទ្រសុខភាពផ្លូវចិត្ត និងផ្លូវអារម្មណ៍) ការថែទាំក្រោយទទួលរងការរំលោភសេពសន្ថវៈ (មធ្យោបាយពន្យារកំណើតបន្ទាន់ ការរំលូតកូនដោយ

3 អង្គការសុខភាពពិភពលោក, ការឆ្លើយតបនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទលើស្ត្រី ៖ គោលការណ៍ណែនាំផ្នែកគ្លីនិក និងគោលនយោបាយរបស់អង្គការសុខភាពពិភពលោក (WHO), ទីក្រុងហ្សឺណែវ ៖ អង្គការសុខភាពពិភពលោក ឆ្នាំ ២០១៣, ទំព័រ ១។

4 អង្គការសុខភាពពិភពលោក, ការឆ្លើយតបនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទលើស្ត្រី ៖ គោលការណ៍ណែនាំផ្នែកគ្លីនិក និងគោលនយោបាយរបស់អង្គការសុខភាពពិភពលោក (WHO), ទីក្រុងហ្សឺណែវ ៖ អង្គការសុខភាពពិភពលោក ឆ្នាំ ២០១៣, ទំព័រទី ១។

សុវត្ថិភាពដែលត្រូវបានអនុញ្ញាតដោយច្បាប់ជាតិ) វិធីបង្ការរោគក្រោយទទួលរងការរំលោភ សេពសន្ថវៈសម្រាប់មេរោគអេដស៍ និងការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺកាមរោគ។ ការបណ្តុះបណ្តាលសម្រាប់អ្នកជំនាញវេជ្ជសាស្ត្រ និងសុខភាពផ្សេងទៀតដើម្បីកំណត់ និងព្យាបាល ស្ត្រីដែលប្រឈមនឹងអំពើហិង្សាដោយប្រសិទ្ធភាព និងការពិនិត្យកោសល្យវិច័យសមស្របដោយអ្នកជំនាញដែលមានការបណ្តុះបណ្តាល ក៏ជាប្រការចាំបាច់ផងដែរ[5] ។ ក្រៅពីនេះ ពួកគេបានប្រើប្រាស់ការណែនាំពីសេចក្តីសន្និដ្ឋានរួមនេះដើម្បីធានាថា សេវាថែទាំសុខភាពមានលក្ខណៈអាច ទទួលបានឆ្លើយតបនឹងការប៉ះទង្គិចផ្លូវចិត្ត អាចលៃលកបាន មានសុវត្ថិភាព និងប្រសិទ្ធភាព និងគុណ ភាពល្អ។

## រូបលេខ ១ ៖ ការថែទាំសុខភាពបឋម និងបរិបទនៃប្រព័ន្ធសុខាភិបាល ការកៀរគរសហគមន៍ និង សកម្មភាពអន្តរវិស័យ




ប្រភព ៖ ដកស្រង់ចេញពី Lawn JE et al, Lancet, ២០០៨, រយៈពេល ៣០ ឆ្នាំរបស់ Alma Ata

5 គណៈកម្មការទទួលបន្ទុកស្ថានភាពស្ត្រី ៖ កិច្ចប្រជុំលើកទី ៥៧ (២០១៣) សេចក្តីសន្និដ្ឋានរួម ៖ ការលុបបំបាត់ និងទប់ស្កាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី និងអង្គការសុខភាពពិភពលោក, ការឆ្លើយតបនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទលើស្ត្រី ៖ គោលការណ៍ណែនាំផ្នែកគ្លីនិកនិងគោលនយោបាយរបស់អង្គការសុខភាពពិភពលោក(WHO), ទីក្រុងហ្សឺណែវ៖អង្គការសុខភាពពិភពលោក ឆ្នាំ ២០១៣។

ការផ្តល់សេវាល្អជាសមាសធាតុដ៏សំខាន់នៃប្រព័ន្ធសុខាភិបាល។ ការរៀបចំ និងខ្លឹមសារសង្ខេបនៃសេវាសុខាភិបាលមានលក្ខណៈខុសគ្នាតាមប្រទេស ប៉ុន្តែអ្នកផ្តល់សេវាសុខភាព "ជាទូទៅ" បំពេញការងារក្នុងកម្រិតផ្សេងៗ ៖

១. ការថែទាំសុខភាពបឋម ដូចជា ប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព និងមន្ទីរព្យាបាល និងមន្ទីរពេទ្យស្រុក ដែលផ្តល់សេវាទូទៅសម្រាប់ជម្ងឺក្រៅ និងសេវាមូលដ្ឋានសម្រាប់ជម្ងឺក្នុង។
២. ការបញ្ជូនទៅរកសេវាថែទាំ រួមមាន មន្ទីរពេទ្យកម្រិតទី ៣ ដែលមានសេវាជំនាញ។ ចំណុចចាប់ផ្តើមសម្រាប់ផ្តល់ការថែទាំដល់ស្ត្រីដែលប្រឈមនឹងអំពើហិង្សា នៅសេវាគ្រប់កម្រិត រួមមាន សុខភាពផ្លូវភេទ និងបន្តពូជ ដូចជា សុខភាពមាតា ការរៀបចំផែនការគ្រួសារ សេវាថែទាំក្រោយរំលូតកូន មេរោគអេដស៍ ជំងឺអេដស៍ និងសេវាសុខភាពផ្លូវចិត្ត ដែលផ្តល់ដោយរដ្ឋាភិបាល ឬ អង្គការមិនមែនរដ្ឋាភិបាល។

ម៉ូឌុលនេះផ្តោតលើសេវាសុខភាពដែលគិតគូរពីប្រជាជន ដោយចាប់ផ្តើមពីបណ្តាញសេវាសុខភាពនៅកម្រិតថែទាំបឋម (ជាជាងកម្រិតជំនាញ ឬមន្ទីរពេទ្យ)។ ម៉ូឌុលនេះកត់សម្គាល់ថា អ្នកផ្តល់ការថែទាំបឋមដល់អ្នកជំងឺជួយត្រួសត្រាយផ្លូវឆ្ពោះទៅរកសេវាចាំបាច់ និងសហការជាមួយ កម្រិត និងប្រភេទអ្នកផ្តល់សេវាផ្សេងៗ។ ក្រៅពីនេះ ក៏មានការសម្របសម្រួលក្នុងវិស័យផ្សេងទៀតផងដែរ (ដូចជា សេវាសង្គម) និងដៃគូ (ដូចជា អង្គការសហគមន៍)។ បណ្តាញនៃការផ្តល់សេវារួមបញ្ចូលសេវាទប់ស្កាត់ ព្យាបាល បន្ធូរបន្ថយ និងស្តារឡើងវិញ និងសកម្មភាពលើកកម្ពស់ សុខភាព[6] ។

## ១.៣ ភាសា និងពាក្យបច្ចេកទេស

ក្នុងបរិបទនៃអំពើហិង្សាបង្កដោយដៃគូស្នេហា ការស្វែងរកករណី និងការសើបសួរផ្នែកគ្លីនិក គឺ សំដៅលើការកំណត់រកស្ត្រីប្រឈមនឹងអំពើហិង្សា ដែលមានវត្តមានក្នុងមជ្ឈដ្ឋានថែទាំសុខភាព តាមរយៈការសួរសំណួរដែលផ្អែកលើស្ថានភាពបច្ចុប្បន្ន ប្រវត្តិ និងការពិនិត្យអ្នកជំងឺក្នុងករណីចាំបាច់។ ពាក្យទាំងនេះត្រូវបានប្រើប្រាស់ខុសគ្នាពីពាក្យ "ការពិនិត្យ" ឬ "ការសាកសួរតាម ទម្លាប់"[7] ។

**ការព្យាបាលបញ្ហាពាក់ព័ន្ធនឹងការរៀនសូត្រ និងអាកប្បកិរិយា (CBT)** ផ្អែកលើទស្សនៈថា គំនិត ដែលមិនមែនជាកត្តាខាងក្រៅ ដូចជា មនុស្ស ឬព្រឹត្តិការណ៍ ជាអ្វីដែលកំណត់អារម្មណ៍ និងអាកប្បកិរិយា។ ជាទូទៅ CBT មានសមាសធាតុផ្នែកខួរក្បាល (ដែលជួយឲ្យមនុស្សអភិវឌ្ឍសមត្ថភាពកំណត់ និងប្រឈមនឹងគំនិតអវិជ្ជមានស្រមើស្រមៃ) និងសមាសធាតុអាកប្បកិរិយា។ CBT ប្រែប្រួលទៅតាមបញ្ហាសុខភាពផ្លូវចិត្តជាក់លាក់[8] ។

6 WHO, ការពិនិត្យតាមដានមូលដ្ឋានគ្រឹះនៃប្រព័ន្ធសុខាភិបាល ៖ សៀវភៅណែនាំសូចនាករ និងយុទ្ធសាស្ត្រវាស់វែង, ទីក្រុងហ្សឺណែវ ៖ WHO ឆ្នាំ ២០១០។

7 អង្គការសុខភាពពិភពលោក, ការឆ្លើយតបនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទលើស្ត្រី ៖ គោលការណ៍ណែនាំផ្នែក គ្លីនិក និងគោលនយោបាយរបស់អង្គការសុខភាពពិភពលោក (WHO), ទីក្រុងហ្សឺណែវ ៖ អង្គការសុខភាពពិភពលោក ឆ្នាំ ២០១៣, ក្នុងសទ្ទានុក្រម ទំព័រ vii។

8 អង្គការសុខភាពពិភពលោក, ការឆ្លើយតបនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទលើស្ត្រី ៖ គោលការណ៍ណែនាំផ្នែក គ្លីនិក និងគោលនយោបាយរបស់អង្គការសុខភាពពិភពលោក (WHO), ទីក្រុងហ្សឺណែវ ៖ អង្គការសុខភាពពិភពលោក ឆ្នាំ ២០១៣, ក្នុងសទ្ទានុក្រមទំព័រ vii។

**សមាសធាតុស្នូល** គឺជាលក្ខណៈពិសេស ឬធាតុផ្សំនៃសេវាសំខាន់ៗដែលអនុវត្តលើគ្រប់បរិបទ និងធានាការបំពេញមុខងាររបស់សេវាប្រកបដោយប្រសិទ្ធភាព។

**សេវាសំខាន់ៗ** រួមបញ្ចូលកញ្ចប់សេវាស្នូលដែលផ្តល់ដោយវិស័យថែទាំសុខភាព សេវាសង្គម វិស័យយុត្តិធម៌ និងការរក្សាសណ្តាប់ធ្នាប់។ យ៉ាងហោចណាស់ សេវាទាំងនេះត្រូវធានាសិទ្ធិសុវត្ថិភាព និងសុខុមាលភាពរបស់ស្ត្រី ឬក្មេងស្រីគ្រប់រូបដែលប្រឈមនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

**ការគាំទ្រជួរមុខ** សំដៅលើកម្រិតអប្បបរមានៃការគាំទ្រ (ផ្តោតលើចិត្តសាស្ត្រ) និងការផ្ទៀងផ្ទាត់បទពិសោធន៍នៃការគាំទ្រសមស្របសម្រាប់ស្ត្រីគ្រប់រូប ដែលបង្ហាញពីករណីអំពើហិង្សាដល់អ្នកផ្តល់ការថែទាំសុខភាព (ឬអ្នកដទៃទៀត)។ វាមានសមាសធាតុរួមជាច្រើនដូចគ្នានឹង "ការសង្គ្រោះបឋមផ្នែកចិត្តសាស្ត្រ" ក្នុងបរិបទនៃស្ថានភាពបន្ទាន់ដែលពាក់ព័ន្ធនឹងការប៉ះទង្គិចផ្លូវចិត្ត[9] ។

**អំពើហិង្សាទាក់ទងនឹងយេនឌ័រ** គឺជា "ការប្រព្រឹត្តអំពើហិង្សាលើស្ត្រី ដោយសារតែគាត់ជាស្ត្រី ឬដែលជះឥទ្ធិពលមិនសមស្របលើស្ត្រី"[10] ។

**អ្នកផ្តល់សេវាសុខភាព** គឺជាបុគ្គល ឬអង្គការដែលផ្តល់សេវាថែទាំសុខភាពជាប្រព័ន្ធ។ អ្នកផ្តល់ការថែទាំសុខភាពម្នាក់អាចជាគ្រូពេទ្យ ភ្នាក់ងារសុខភាពសហគមន៍ ឬបុគ្គលផ្សេងទៀតដែលទទួលការបណ្តុះបណ្តាល និងមានចំណេះដឹងផ្នែកសុខាភិបាល។ ស្ថាប័នសុខភាពនានារួមមានមន្ទីរពេទ្យគ្លីនិកមជ្ឈមណ្ឌលថែទាំបឋមនិងកន្លែងផ្តល់សេវាផ្សេងទៀត។អ្នកផ្តល់ការថែទាំសុខភាពបឋមរួមមាន គិលានុបដ្ឋាក ឆ្មប វេជ្ជបណ្ឌិត[11] ។ល។

**ប្រព័ន្ធសុខាភិបាល** សំដៅលើ (១) សកម្មភាពទាំងអស់ដែលផ្តោតសំខាន់លើការលើកកម្ពស់ ស្តារ និង/ឬ រក្សាសុខភាព (២) ប្រជាជន ស្ថាប័ន និងធនធានដែលត្រូវបានរៀបចំជារួមដោយផ្អែកតាមគោលនយោបាយដែលបង្កើតឡើងដើម្បីបង្កើនសុខភាពរបស់ប្រជាជន[12] ។

---

9 អង្គការសុខភាពពិភពលោក, ការឆ្លើយតបនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទលើស្ត្រី ៖ គោលការណ៍ណែនាំគ្លីនិក និងគោលនយោបាយរបស់អង្គការសុខភាពពិភពលោក (WHO), ទីក្រុងហ្សឺណែវ ៖ អង្គការសុខភាពពិភពលោក ឆ្នាំ ២០១៣, ក្នុងសទ្ទានុក្រម។ សម្រាប់ខ្លឹមសារលម្អិត សូមមើល អង្គការ WHO, UNFPA និង UN Women ៖ ការថែទាំសុខភាពសម្រាប់ ស្ត្រីដែលប្រឈមនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា ឬអំពើហិង្សាផ្លូវភេទ, សៀវភៅណែនាំគ្លីនិក ទីក្រុងហ្សឺណែវ ៖ WHO ឆ្នាំ ២០១៤។

10 CEDAW, អនុសាសន៍រួមលេខ ១៩ កថាខណ្ឌ ៦ ៖ http://www.un.org/womenwatch/daw/cedaw/recommendations/recomm.htm។

11 អង្គការសុខភាពពិភពលោក, ការឆ្លើយតបនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទលើស្ត្រី ៖ គោលការណ៍ណែនាំផ្នែកគ្លីនិក និងគោលនយោបាយរបស់អង្គការសុខភាពពិភពលោក (WHO), ទីក្រុងហ្សឺណែវ ៖ អង្គការសុខភាពពិភពលោក ឆ្នាំ ២០១៣, ក្នុងសទ្ទានុក្រម ទំព័រ vii។

12 WHO, ការពង្រឹងប្រព័ន្ធសុខាភិបាល ៖ សទ្ទានុក្រម។ ដកស្រង់ចេញពីគេហទំព័រ ៖ www.who.int/healthsystems/Glossary_January2011.pdf។

**អំពើហិង្សាបង្កដោយដៃគូស្នេហា** គឺជា "ទម្រង់ទូទៅបំផុតនៃអំពើហិង្សាដែលប្រព្រឹត្តលើស្ត្រីទូទាំងពិភពលោក...និងរួមបញ្ចូលការបង្ខិតបង្ខំផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទលើស្ត្រីពេញវ័យ និងស្ត្រីជំទង់ដោយដៃគូស្នេហាបច្ចុប្បន្ន ឬពីមុន ដោយគ្មានការយល់ព្រមពីស្ត្រី។ អំពើហិង្សាផ្លូវកាយរួមមានការប្រើប្រាស់កម្លាំងកាយ ឬអាវុធដើម្បីបង្ករបួស ឬគ្រោះថ្នាក់ដល់ស្ត្រី។ អំពើហិង្សាផ្លូវភេទរួមមានការប្រទូស្តកេរ្តិ៍ភេទ ការធ្វើឲ្យស្ត្រីពាក់ព័ន្ធក្នុងផ្លូវភេទដោយគ្មានការយល់ព្រមពីស្ត្រី និងការប៉ុនប៉ងរំលោភផ្លូវភេទ ឬការរំលោភផ្លូវភេទបានសម្រេចជាមួយស្ត្រីដែលមានជំងឺពិការ និងទទួល រងសម្ពាធ ឬស្ថិតក្រោមឥទ្ធិពលគ្រឿងស្រវឹង ឬគ្រឿងញៀនផ្សេងៗ។ អំពើហិង្សាផ្លូវចិត្តរួមបញ្ចូលការគ្រប់គ្រង ឬការដាក់ឲ្យស្ត្រីឯកោរ និងការប្រមាថ ឬបង្កក្តីអាម៉ាស់ដល់ស្ត្រី។ អំពើហិង្សាផ្នែកសេដ្ឋកិច្ចរួមមានការបដិសេធមិនឲ្យស្ត្រីទទួលបាន និងគ្រប់គ្រងធនធានសំខាន់ៗ"[13] ។

**កាតព្វកិច្ចរាយការណ៍** សំដៅលើច្បាប់ដែលអនុម័តដោយប្រទេស ឬរដ្ឋមួយចំនួនដែលតម្រូវឲ្យបុគ្គល ឬអ្នកទទួលការចាត់តាំង ដូចជា អ្នកផ្តល់ការថែទាំសុខភាព ឲ្យរាយការណ៍ (ជាទូទៅរាយការណ៍ទៅនគរបាល ឬប្រព័ន្ធច្បាប់) ពីករណីជាក់ស្តែង ឬករណីសង្ស័យនៃអំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាបង្កដោយដៃគូស្នេហា។ ក្នុងប្រទេសជាច្រើន កាតព្វកិច្ចរាយការណ៍អនុវត្តចំពោះការរំលោភបំពានកុមារ និងការធ្វើទុក្ខបុកម្នេញអនីតិជន ប៉ុន្តែក្នុងប្រទេសផ្សេងទៀត កាតព្វកិច្ចរាយការណ៍ បានគ្របដណ្តប់រហូតដល់ ការរាយការណ៍ពីករណីអំពើហិង្សាបង្កដោយដៃគូស្នេហា[14] ។

**ភស្តុតាងផ្នែកវេជ្ជសាស្ត្រ-ច្បាប់** ត្រូវបានប្រើប្រាស់ក្នុងឧបករណ៍នេះទៅតាមការកំណត់និយមន័យដោយអង្គការសុខភាពពិភពលោកថាជា "ការចងក្រងឯកសារស្តីពីរបួសទ្វារធំ-ប្រដាប់ភេទ និងការរងរបួសបន្ថែម ស្ថានភាពផ្លូវចិត្ត និងវត្ថុវិភាគដែលយកចេញពីរាងកាយ ឬសម្លៀកបំពាក់របស់ជនរងគ្រោះសម្រាប់គោលបំណងផ្នែកច្បាប់។ ភស្តុតាងទាំងនេះរួមមាន ទឹកមាត់ ទឹកកាមសក់ រោមប្រដាប់ភេទ ឈាម ទឹកនោម សរសៃក្រណាត់ កាកសំណល់ និងដី "[15]។

**អំពើហិង្សាផ្លូវភេទបង្កដោយអ្នកមិនមែនជាដៃគូ** "សំដៅលើអំពើហិង្សាដែលបង្កឡើងដោយសាច់ញាតិ មិត្តភក្តិ មនុស្សស្គាល់គ្នា អ្នកជិតខាង សហសេវិក ឬមនុស្សប្លែកមុខ "[16]។ វារួមបញ្ចូលការទទួលរងការបង្ខិតបង្ខំឲ្យប្រព្រឹត្តផ្លូវភេទដោយមិនចង់ ការបៀតបៀនផ្លូវភេទ និងអំពើហិង្សា

13 របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ, ការសិក្សាស៊ីជម្រៅស្តីពីរាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី, អង្គការសហប្រជាជាតិ, A/61/122/Add.1, (ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០០៦), កថាខណ្ឌ ១១១-១១២ ៖ http://daccess-ddsny.un.org/doc/UNDOC/GEN/N06/419/74/PDF/N0641974.pdf?OpenElement។

14 អង្គការសុខភាពពិភពលោក, ការឆ្លើយតបនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទលើស្ត្រី ៖ គោលការណ៍ណែ នាំផ្នែកគ្លីនិក និងគោលនយោបាយរបស់អង្គការសុខភាពពិភពលោក (WHO), ទីក្រុងហ្សឺណែវ ៖ អង្គការសុខភាពពិភពលោក ឆ្នាំ ២០១៣, ក្នុងសទ្ទានុក្រម ទំព័រ vii។

15 Du Mont, Janice និង D. White (២០០៧), "ការប្រើប្រាស់ និងផលប៉ះពាល់នៃភស្តុតាងផ្នែកវេជ្ជសាស្ត្រ-ច្បាប់ក្នុងករណីបៀតបៀនផ្លូវភេទ ៖ ការពិនិត្យឡើងវិញជាសកល (WHO:ទីក្រុងហ្សឺណែវ) និង WHO, គោលការណ៍ណែនាំស្តីពីការថែទាំផ្នែកវេជ្ជសាស្ត្រ-ច្បាប់សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ។ ទីក្រុងហ្សឺណែវ ៖ WHO ឆ្នាំ ២០០៣។

16 របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ, ការសិក្សាស៊ីជម្រៅស្តីពីរាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី, អង្គការសហប្រជាជាតិ, A/61/122/Add.1, (ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០០៦), កថាខណ្ឌ ១២៨ ៖ http://daccess-ddsny.un.org/doc/UNDOC/GEN/N06/419/74/PDF/N0641974.pdf?OpenElement។

ដែលប្រព្រឹត្តជាញឹកញាប់លើស្ត្រី និងក្មេងស្រីដោយជនល្មើសដែលពួកគេស្គាល់ ដូចជាក្នុងទីសាធារណៈ សាលារៀន កន្លែងធ្វើការ និងសហគមន៍។

**គោលការណ៍ណែនាំស្តីពីគុណភាព** គាំទ្រការផ្តល់ និងការអនុវត្តសមាសធាតុស្នូលនៃសេវាសំខាន់ៗដើម្បីធានាថា វាមានប្រសិទ្ធភាព និងមានគុណភាពគ្រប់គ្រាន់ក្នុងការដោះស្រាយតម្រូវការរបស់ស្ត្រី និងក្មេងស្រី។ គោលការណ៍ណែនាំនេះបង្ហាញពី "របៀប" ផ្តល់សេវាតាមវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស គិតគូរពីវប្បធម៌ និងបង្កើនភាពអង់អាចរបស់ស្ត្រី។ វាផ្អែកលើ និងបំពេញឲ្យស្តង់ដាអន្តរជាតិ ព្រមទាំងឆ្លុះបញ្ចាំងពីការអនុវត្តល្អបំផុតដែលមានការទទួលស្គាល់ ក្នុងការឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

**ជនរងគ្រោះ** សំដៅលើស្ត្រី និងក្មេងស្រីដែលប្រឈម ឬទទួលរងអំពើហិង្សាទាក់ទងនឹងយេនឌ័រដើម្បីឆ្លុះបញ្ចាំងពីពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងដំណើរការផ្លូវច្បាប់ និងទីភ្នាក់ងាររបស់ ស្ត្រី និងក្មេងស្រីក្នុងការស្វែងរកសេវាសំខាន់ៗ[17] ។

**អំពើហិង្សាលើស្ត្រី** (VAW) សំដៅលើ "ការប្រព្រឹត្តអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលបង្កជា ឬនឹងបង្កជាគ្រោះថ្នាក់ ឬការឈឺចាប់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្ត និងផ្លូវអារម្មណ៍លើស្ត្រី ដូចជាការគំរាមកំហែង ការបង្ខិតបង្ខំ ឬការដកហូតសេរីភាពតាមទំនើងចិត្ត មិនថាកើតមានក្នុងជីវិតសាធារណៈ ឬជីវិតឯកជនឡើយ[18] ។

17 អង្គការសហប្រជាជាតិ (២០០៦) ការសិក្សាស៊ីជម្រៅរបស់អគ្គលេខាអង្គការសហប្រជាជាតិស្តីពីអំពើហិង្សាលើស្ត្រី A/61/122/Add.1 កត់សម្គាល់ពីការជជែកដេញដោលជាបន្តបន្ទាប់ស្តីពីពាក្យជនរងគ្រោះ-victim/survivor។ អ្នកខ្លះលើកឡើង ថា មិនគួរប្រើ "ពាក្យជនរងគ្រោះ-victim" ទេ ព្រោះវាបង្ហាញពីភាពអកម្ម ភាពទន់ខ្សោយ និងបង្កប់ភាពងាយរងគ្រោះ និងមិនទទួលស្គាល់តថភាពនៃភាពធន់របស់ស្ត្រី និងទីភ្នាក់ងារ។ សម្រាប់អ្នកផ្សេងទៀត ពាក្យ "ជនរងគ្រោះ-survivor" បង្កជាបញ្ហា ព្រោះវាបដិសេធខ្លឹមសារនៃការរងគ្រោះដែលប្រឈមដោយស្ត្រីដែលជាគោលដៅនៃបទឧក្រិដ្ឋហិង្សា"។ ដូច្នេះ គោលការណ៍ណែនាំទាំងនេះប្រើប្រាស់ពាក្យ "ជនរងគ្រោះ-victim/survivor"។

18 អង្គការសហប្រជាជាតិ ឆ្នាំ ១៩៩៣, សេចក្តីប្រកាសស្តីពីការលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី, អង្គការសហប្រជាជាតិ ៖ ទីក្រុងហ្សឺណែវ, មាត្រា ១។

# ជំពូក ២ ៖ ក្របខណ្ឌសម្រាប់កញ្ចប់សេវាសំខាន់ៗ

## ២.១ ក្របខណ្ឌទូទៅ

ក្របខណ្ឌគោលការណ៍ណែនាំស្តីពីការផ្តល់សេវាសំខាន់ៗដែលមានគុណភាព រួមបញ្ចូលសមាសភាគប្រទាក់ក្រឡាគ្នាចំនួនបួន ៖

- គោលការណ៍ ដែលគាំទ្រការផ្តល់សេវាសំខាន់ៗទាំងអស់។
- លក្ខណៈទូទៅ ដែលរៀបរាប់ពីកញ្ចប់សកម្មភាព និងវិធីសាស្ត្រដែលមានលក្ខណៈសាមញ្ញគ្រប់ផ្នែក និងគាំទ្រការបំពេញមុខងារ និងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព។
- សេវាសំខាន់ៗ ដែលកំណត់ពីសេវាចាំបាច់អប្បបរមាសំខាន់ៗដើម្បីធានាសិទ្ធិមនុស្ស សុវត្ថិភាព និងសុខុមាលភាពរបស់ស្ត្រី ក្មេងស្រីជំទង់ដែលប្រឈមនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា ឬអំពើហិង្សាផ្លូវភេទបង្កដោយអ្នកមិនមែនជាដៃគូ។
- សមាសធាតុគ្រឹះ ដែលត្រូវមានជាស្រេចដើម្បីជំរុញការផ្តល់សេវាដែលមានគុណភាពលើគ្រប់សេវាសំខាន់ៗ និងសកម្មភាពទាំងអស់។

### កញ្ចប់សេវាសំខាន់ៗ ៖ ដ្យាក្រាមក្របខណ្ឌទូទៅ

| | | | |
|---|---|---|---|
| គោលការណ៍ | វិធីសាស្ត្រផ្អែកតាមសិទ្ធិ | ពង្រឹងសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រី | សមស្របតាមវប្បធម៌ និងអាយុ |
| | វិធីសាស្ត្រផ្តោតលើជនរងគ្រោះ | សុវត្ថិភាពជាចម្បង | ការទទួលខុសត្រូវរបស់ជនបង្ក |

| | | |
|---|---|---|
| លក្ខណៈទូទៅ | ភាពអាចរកបាន | ភាពអាចទទួលបាន |
| | ភាពអាចសម្របតាមបាន | ភាពសមស្រប |
| | សុវត្ថិភាពជាចម្បង | ការយល់ព្រមត្រឹមត្រូវ និងការសម្ងាត់ |
| | ការប្រមូលទិន្នន័យនិងការគ្រប់គ្រងព័ត៌មាន | ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព |
| | ការផ្សារភ្ជាប់ជាមួយវិស័យ និងទីភ្នាក់ងារផ្សេងៗតាមរយៈការបញ្ជូន និងការសម្របសម្រួល | |

| | សុខភាព | យុត្តិធម៌ និងការរក្សាសណ្តាប់ធ្នាប់ | សេវាសង្គម |
|---|---|---|---|
| | ១. កំណត់រកជនរងគ្រោះដោយសារអំពើហិង្សាបង្កដោយដៃគូស្នេហា | ១. ការទប់ស្កាត់ | ១. ព័ត៌មានពីវិបត្តិ |
| | ២. ការគាំទ្រជួរមុខ | ២. ព័ត៌មានទាក់ទងដំបូង | ២. ការផ្តល់ប្រឹក្សាស្តីពីវិបត្តិ |
| | ៣. ការថែទាំរបួស និងការ | ៣. ការវាយតម្លៃ/ការស៊ើបអង្កេត | ៣. លេខទូរស័ព្ទជំនួយ |
| | | ៤. ដំណើរការមុនការកាត់ទោស | ៤. ជម្រកសុវត្ថិភាព |
| | | ៥. ដំណើរការកាត់ទោស | ៥. ជំនួយសម្ភារ និងហិរញ្ញវត្ថុ |

| | | | |
|---|---|---|---|
| សេវាសំខាន់ៗ និងសកម្មភាព | ព្យាបាលផ្នែកវេជ្ជសាស្ត្របន្ទាន់<br>៤. ការពិនិត្យការបៀតបៀនផ្លូវភេទ និងការថែទាំ<br>៥. ការវាយតម្លៃសុខភាពផ្លូវចិត្ត និងការថែទាំ<br>៦. ការចងក្រងឯកសារ (វេជ្ជសាស្ត្រ-ច្បាប់) | ៦. ការទទួលខុសត្រូវរបស់ជនបង្ក និងការផ្តល់សំណង<br>៧. ដំណើរការក្រោយការកាត់ទោស<br>៨. សុវត្ថិភាព និងការការពារ<br>៩. ជំនួយ និងការគាំទ្រ<br>១០. ទំនាក់ទំនង និងព័ត៌មាន<br>១១. ការសម្របសម្រួលផ្នែកយុត្តិធម៌ | ៦. ការបង្កើត ការរកឃើញមកវិញ និងការជំនួសឯកសារអត្តសញ្ញាណ<br>៧. ព័ត៌មានស្តីពីច្បាប់ និងសិទ្ធិ ដំបូន្មាន និងការតំណាង ដូចជាក្នុងប្រព័ន្ធច្បាប់ចម្រុះ<br>៨. ការគាំទ្រចិត្តសង្គម និងការផ្តល់ប្រឹក្សា<br>៩. ការគាំទ្រស្ត្រី<br>១០. សេវាកុមារសម្រាប់កុមារដែលរងគ្រោះដោយសារអំពើហិង្សា<br>១១. ព័ត៌មានសហគមន៍ ការអប់រំ និងការចុះតាមសហគមន៍<br>១២. ការផ្តល់ជំនួយឲ្យមានលំនឹងសេដ្ឋកិច្ច ការជាសះ និងស្វ័យភាព |

## ការសម្របសម្រួល និងការគ្រប់គ្រងការងារសម្របសម្រួល

**ថ្នាក់ជាតិ ៖ សកម្មភាពសំខាន់ៗ**

១. ការតាក់តែងច្បាប់ និងគោលនយោបាយ
២. ភាពសមស្រប និងការបែងចែកធនធាន
៣. ការកំណត់បទដ្ឋានសម្រាប់បង្កើតការឆ្លើយតបដែលមានការសម្របសម្រួលនៅថ្នាក់មូលដ្ឋាន
៤. វិធីសាស្ត្រដែលមានលក្ខណៈរួមបញ្ចូលដើម្បីឲ្យមានការឆ្លើយតបដែលមានការសម្របសម្រួល
៥. សម្របសម្រួលការអភិវឌ្ឍសមត្ថភាពរបស់អ្នកតាក់តែងគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្តផ្សេងទៀតស្តីពីការការឆ្លើយតបដែលមានការសម្របសម្រួលទៅនឹងអំពើហិង្សាលើស្ត្រី និងក្មេងស្រី
៦. ពិនិត្យតាមដាន និងវាយតម្លៃការសម្របសម្រួលនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន

**ថ្នាក់មូលដ្ឋាន ៖ សកម្មភាពសំខាន់ៗ**

១. ការបង្កើតរចនាសម្ព័ន្ធផ្លូវការសម្រាប់ការសម្របសម្រួលតាមមូលដ្ឋាន និងការគ្រប់គ្រងការងារសម្របសម្រួល
២. ការអនុវត្តការសម្របសម្រួល និងការគ្រប់គ្រងការងារសម្របសម្រួល

| សមាសធាតុគ្រឹះ | | | |
|---|---|---|---|
| | ក្របខណ្ឌច្បាប់ និង គតិយុត្តិគ្រប់ជ្រុងជ្រោយ | អភិបាលកិច្ច ការត្រួតពិនិត្យ និងគណនេយ្យភាព | ធនធាន និងហិរញ្ញប្បទាន |
| | ការបណ្តុះបណ្តាល និងការអភិវឌ្ឍកម្លាំងពលកម្ម | គោលនយោបាយ និងការអនុវត្តដែលគិតគូរពីយេនឌ័រ | ការពិនិត្យតាមដាន និង វាយតម្លៃ |

## ២.២ លក្ខណៈពិសេសនៃក្របខណ្ឌសម្រាប់សេវាសុខភាពសំខាន់ៗ

### គោលការណ៍

ក្នុងការអនុវត្តគោលការណ៍ទាំងអស់ អ្នកផ្តល់សេវាសុខភាពគួរចងចាំចំណុចខាងក្រោម ៖

- វិធីសាស្ត្រផ្អែកតាមសិទ្ធិ រួមបញ្ចូលសិទ្ធិទទួលបានស្តង់ដាសុខភាពខ្ពស់បំផុតដែលអាចសម្រេចបាន និងសិទ្ធិស្វ័យសម្រេចចិត្ត ពោលគឺសំដៅលើស្ត្រីដែលមានសិទ្ធិធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង ដូចជា ពាក់ព័ន្ធនឹងផ្លូវភេទ និងសុខភាពបន្តពូជ មានសិទ្ធិមិនទទួលយកនីតិវិធីវេជ្ជសាស្ត្រ និង/ឬចាត់វិធានការផ្លូវច្បាប់[19] ។
- ការធានាសមភាពយេនឌ័រក្នុងវិស័យសុខាភិបាល សំដៅលើការផ្តល់ការថែទាំដោយស្មើភាពដល់ស្ត្រី និងបុរសដោយពិចារណាពីតម្រូវការ និងបញ្ហាសុខភាពរបស់ពួកគេ ដើម្បីឲ្យពួកគេមានលទ្ធភាពដូចគ្នាក្នុងការទទួលបានសិទ្ធិ និងសុខភាពល្អ។ ក្រៅពីនេះ វាតម្រូវឲ្យមានការទទួលស្គាល់វិសមភាពនៃទំនាក់ទំនងអំណាចរវាងស្ត្រី និងបុរស និងរវាងអ្នកផ្តល់សេវា និងអ្នកជំងឺ។

### លក្ខណៈទូទៅ

ក្នុងការអនុវត្តគោលការណ៍ទូទៅ អ្នកផ្តល់សេវាសុខភាពគួរចងចាំចំណុចខាងក្រោម ៖

- ការយល់ព្រមត្រឹមត្រូវនិងការធានារក្សាការសម្ងាត់មានន័យថាការផ្តល់ការថែទាំសុខភាព ការព្យាបាល និងការផ្តល់ប្រឹក្សា គួរមានលក្ខណៈឯកជន និងរក្សាការសម្ងាត់ ហើយព័ត៌មានត្រូវបានលាតត្រដាងដោយមានការយល់ព្រមពីស្ត្រី និងរួមបញ្ចូលសិទ្ធិដឹងលឺព័ត៌មានដែលត្រូវបានប្រមូលស្តីពីសុខភាពរបស់ពួកគាត់ និងការមានលទ្ធភាពទទួលបានព័ត៌មានទាំងនេះ ដូចជា កំណត់ត្រាវេជ្ជសាស្ត្រ[20] ។

### សមាសធាតុគ្រឹះ

ក្នុងការអនុវត្តគោលការណ៍ទូទៅ អ្នកផ្តល់សេវាសុខភាពគួរចងចាំចំណុចខាងក្រោម ៖

- គោលនយោបាយស្តីពីអំពើហិង្សាលើស្ត្រី និងសុខភាពត្រូវពាក់ព័ន្ធនឹងគោលនយោបាយជាតិ

19 អង្គការ WHO, UNFPA និង UN Women ៖ ការថែទាំសុខភាពសម្រាប់ស្ត្រីដែលប្រឈមនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា ឬអំពើហិង្សាផ្លូវភេទ, សៀវភៅណែនាំគ្លីនិក ទីក្រុងហ្សឺណែវ ៖ WHO ឆ្នាំ ២០១៤ (WHO/RHR/14.26) ទំព័រ ៣។

20 អង្គការ WHO, UNFPA និង UN Women ៖ ការថែទាំសុខភាពសម្រាប់ស្ត្រីដែលប្រឈមនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា ឬអំពើហិង្សាផ្លូវភេទ, សៀវភៅណែនាំគ្លីនិក ទីក្រុងហ្សឺណែវ ៖ WHO ឆ្នាំ ២០១៤ (WHO/RHR/14.26) ទំព័រទី ៣។

រួមបញ្ចូលការដោះស្រាយអំពើហិង្សាក្នុងកន្លែងការងារ/ស្ថាប័ន និងរួមបញ្ចូលនីតិវិធីដៃគូ/សហការ និងពិធីសារ។ ការថែទាំសម្រាប់ស្ត្រីដែលប្រឈមនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទ គួរត្រូវបានរួមបញ្ចូលទៅក្នុងសេវាសុខាភិបាលមានស្រាប់ក្នុងកម្រិតខ្ពស់បំផុត ជាជាងត្រឹមតែជាសេវាដាច់ដោយឡែកមួយ[21] ។

- ការអភិវឌ្ឍកម្លាំងពលកម្មក្នុងវិស័យសុខាភិបាល រួមមានការកសាងសមត្ថភាពស្តីពីបញ្ហាទាំងនេះក្នុងការបណ្តុះបណ្តាលមុនពេលបម្រើការ និងតាមរយៈការអប់រំជាបន្តបន្ទាប់ និងការបណ្តុះបណ្តាលក្នុងពេលបម្រើការ។ ក្រៅពីនេះ វាទាមទារនូវការបង្កើតក្រុមចម្រុះ វិស័យ និងការគ្រប់គ្រង និងពិនិត្យតាមដានកម្លាំងការងារសុខាភិបាល។ ខណៈដែលប្រទេសមួយត្រូវការគំរូចម្រុះនៃការថែទាំសម្រាប់ជនរងគ្រោះ នៅកម្រិតផ្សេងៗនៃប្រព័ន្ធសុខាភិបាល គេគួរផ្តោតអាទិភាពលើការកសាងសមត្ថភាព និងការផ្តល់សេវានៅកម្រិតថែទាំបឋម[22] ។ លើសពីនេះ គួរមានអ្នកផ្តល់ការថែទាំសុខភាព (គិលានុបដ្ឋាក គ្រូពេទ្យ ឬសមមូល) ដែលទទួលបានការបណ្តុះបណ្តាលស្តីពីការថែទាំ និងពិនិត្យការបៀតបៀនផ្លូវភេទដែលគិតគូរពីយេនឌ័រ ប្រចាំការគ្រប់ពេលទាំងថ្ងៃ ទាំងយប់ (នៅនឹងកន្លែង ឬទូរស័ព្ទ) នៅថ្នាក់ស្រុក ឬតំបន់[23] ។
- ការចូលរួមជាមួយសហគមន៍ និងការគាំទ្រជនរងគ្រោះជាស្ត្រី និងក្មេងស្រីគឺជាមូលដ្ឋានដ៏សំខាន់នៃសេវាសុខភាពសំខាន់ៗសម្រាប់ជនរងគ្រោះ។
- សមាសធាតុដ៏សំខាន់មួយទៀតសម្រាប់សេវាសុខាភិបាលគឺការមានផលិតផលវេជ្ជសាស្ត្រ ឬទំនិញ និងបច្ចេកវិទ្យា ដូចជា សន្តិសុខទំនិញសុខភាពបន្តពូជ និងមជ្ឈដ្ឋានជុំវិញដើម្បីរក្សាការសម្ងាត់ ភាពឯកជន និងសុវត្ថិភាព។
- ការពិនិត្យតាមដាន និងវាយតម្លៃសេវាសុខភាពសំខាន់ៗត្រូវការប្រព័ន្ធព័ត៌មានសុខាភិបាល វិធានការគណនេយ្យភាព ព័ត៌មានត្រឡប់និងការវាយតម្លៃពី អ្នកជំងឺ។

21 អង្គការសុខភាពពិភពលោក, ការឆ្លើយតបនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទលើស្ត្រី ៖ គោលការណ៍ណែនាំផ្នែក គ្លីនិក និងគោលនយោបាយរបស់អង្គការសុខភាពពិភពលោក (WHO), ទីក្រុងហ្សឺណែវ ៖ អង្គការសុខភាពពិភពលោក ឆ្នាំ ២០១៣, អនុសាសន៍លេខ ៣៤។

22 អង្គការសុខភាពពិភពលោក, ការឆ្លើយតបនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទលើស្ត្រី ៖ គោលការណ៍ណែនាំផ្នែក គ្លីនិក និងគោលនយោបាយរបស់អង្គការសុខភាពពិភពលោក (WHO), ទីក្រុងហ្សឺណែវ ៖ អង្គការសុខភាពពិភពលោក ឆ្នាំ ២០១៣, អនុសាសន៍លេខ ៣៥។

23 អង្គការសុខភាពពិភពលោក, ការឆ្លើយតបនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទលើស្ត្រី ៖ គោលការណ៍ណែនាំផ្នែក គ្លីនិក និងគោលនយោបាយរបស់អង្គការសុខភាពពិភពលោក (WHO), ទីក្រុងហ្សឺណែវ ៖ អង្គការសុខភាពពិភពលោក ឆ្នាំ ២០១៣, អនុសាសន៍លេខ ៣៦។

# ជំពូក ៣ ៖ គោលការណ៍ណែនាំសម្រាប់សេវាសុខភាពសំខាន់ៗ

ម៉ូឌុលនេះគួរត្រូវបានអានរួមគ្នានឹងគោលការណ៍ណែនាំគ្លីនិក និងគោលនយោបាយរបស់អង្គការ WHO និងសៀវភៅណែនាំគ្លីនិកដែលត្រូវបានតាក់តែងឡើងរួមគ្នាដោយអង្គការ WHO អង្គការ UN Women និងអង្គការ UNFPA ស្តីពីការថែទាំសុខភាពសម្រាប់ស្ត្រីប្រឈមនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា ឬអំពើហិង្សាផ្លូវភេទ។ ព័ត៌មានខាងក្រោមនេះសង្ខេបពីចំណុចសំខាន់ៗមួយចំនួន ដែលដកស្រង់ចេញពីឯកសារទាំងនោះ ជាពិសេសសៀវភៅណែនាំគ្លីនិក។

| សេវាសំខាន់ៗ ៖ ១. ការកំណត់រកជនរងគ្រោះដោយសារអំពើហិង្សាបង្កដោយដៃគូស្នេហា | |
|---|---|
| អ្នកផ្តល់សេវាសុខភាពត្រូវដឹងថា បញ្ហាសុខភាពរបស់ស្ត្រីអាចបង្កឡើង ឬកាន់តែអាក្រក់ឡើងដោយសារអំពើហិង្សា។ ជារឿយៗ ស្ត្រីដែលប្រឈមនឹងអំពើហិង្សាដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទច្រើនស្វែងរកសេវាសុខភាពទាក់ទងនឹងបញ្ហាផ្លូវចិត្ត ឬរាងកាយ ដូចជា ការរងរបួសជាដើម។ យ៉ាងណាក៏ដោយ ជារឿយៗ ស្ត្រីទាំងនោះមិនបានប្រាប់អ្នកផ្តល់សេវាសុខភាពពីអំពើហិង្សាដែលកើតឡើងលើពួកគេឡើយ ដោយសារតែការអៀនខ្មាស់ ឬរងការម៉ាក់ងាយ ឬខ្លាចដៃគូស្នេហារបស់ខ្លួន។ | |
| សមាសធាតុស្នូល | គោលការណ៍ណែនាំ |
| **១.១ ព័ត៌មាន** | • នៅកន្លែងថែទាំ សុខភាព គួរតែមានព័ត៌មានជាលាយលក្ខណ៍អក្សរពីអំពើហិង្សាបង្កដោយដៃគូស្នេហា និងការបៀតបៀនផ្លូវភេទបង្កដោយអ្នកមិនមែនជាដៃគូ ក្នុងទម្រង់ជាផ្ទាំងរូបភាព និងលិខិតខ្លី ឬខិតប័ណ្ណនៅតាមកន្លែងឯកជន ដូចជា បន្ទប់ទឹកស្ត្រី (ដោយមានការហាមប្រាមមិនឲ្យយកឯកសារទាំងនោះទៅផ្ទះ ប្រសិនបើដៃគូបង្កអំពើហិង្សាស្ថិតនៅទីនោះដែរ)។ (គោលការណ៍ណែនាំរបស់អង្គការ WHO ៖ អនុសាសន៍លេខ ៨) |
| **១.២ កំណត់រកស្ត្រីដែលរងគ្រោះដោយសារអំពើហិង្សាបង្កដោយដៃគូស្នេហា** | • អ្នកផ្តល់សេវាសុខភាព គួរសាកសួរពីការប្រឈមនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា នៅពេលវាយតម្លៃស្ថានភាពដែលអាចបណ្តាលមកពី ឬពាក់ព័ន្ធនឹងអំពើហិង្សាបង្កដោយដៃគូស្នេហាដើម្បីឲ្យការធ្វើរោគវិនិច្ឆ័យ ឬការកំណត់រក និងការថែទាំជាបន្តបន្ទាប់កាន់តែប្រសើរឡើង។<br>(សូមមើលប្រអប់ទី ១ ទំព័រ ១៩ ក្នុងគោលការណ៍ណែនាំរបស់អង្គការWHO និងទំព័រ ៩ នៃសៀវភៅណែនាំគ្លីនិកទាក់ទងនឹងស្ថានភាព គ្លីនិក និងស្ថានភាពផ្សេងទៀតដែលពាក់ព័ន្ធអំពើហិង្សាបង្កដោយដៃគូស្នេហា) |

| | |
|---|---|
| | • សាកសួរស្ត្រីពីអំពើហិង្សា ត្រូវតែភ្ជាប់មកជាមួយនឹង ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ដូចជា ការគាំទ្រជួរមុខ ការព្យាបាល និងការថែទាំសមស្រប និងការបញ្ជូនបន្តនៅក្នុង ប្រព័ន្ធសុខាភិបាលផ្ទាល់ ឬបញ្ជូនបន្តទៅផ្នែកផ្សេងទៀត។<br>• "ការពិនិត្យជាសកល" ឬ "ការសាកសួរតាមទម្លាប់" (ឧទាហរណ៍ការសាកសួរស្ត្រីនៅកន្លែងចុះឈ្មោះក្នុងមណ្ឌលសុខភាព) មិនគួរត្រូវបានអនុវត្តឡើយ។ ខណៈដែលការធ្វើដូច្នេះ អាចបង្កើនលទ្ធភាពកំណត់រកស្ត្រីរងគ្រោះដោយសារអំពើហិង្សា តែវាមិនបានផ្តល់ភាពល្អ ប្រសើរដល់លទ្ធផលសុខភាព ឬការបញ្ជូនបន្តនោះឡើយ ។ វាពិតជាមានការលំបាកសម្រាប់ការអនុវត្តបែបនេះក្នុងមណ្ឌលសុខភាព ដែលមានករណីអំពើហិង្សាកើតឡើងច្រើន និងខ្វះធនធាន ឬជម្រើសក្នុងការបញ្ជូន។<br>• មុនពេលសួរសំណួរ ទាក់ទងនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា ប្រព័ន្ធសុខាភិបាល គួរត្រៀមរួចជាស្រេចនូវលក្ខខណ្ឌអប្បបរមាដូចខាងក្រោម ៖<br>• កន្លែងឯកជន<br>• អ្នកផ្តល់សេវាសុខភាព ដែលទទួលបានការបណ្តុះបណ្តាលពីរបៀបសួរសំណួរឲ្យបានសមស្រប (ឧទាហរណ៍ ក្នុងលក្ខណៈមួយដែលយល់ចិត្ត មិនវិនិច្ឆ័យ) និងរបៀបឆ្លើយតបឲ្យបានសមស្រប<br>• រៀបចំជាស្រេចនូវប្រព័ន្ធសម្រាប់បញ្ជូនបន្ត<br>• រៀបចំជាស្រេចនូវនីតិវិធីប្រតិបត្តិស្តង់ដា/ពិធីសារ<br>(សូមមើលគោលការណ៍ណែនាំរបស់អង្គការ WHO ៖ អនុសាសន៍លេខ ២ និង ៣ និងសៀវភៅណែនាំគ្លីនិក, ទំព័រ ១០-១២) |
| ១.២ កំណត់រកស្ត្រីដែលរងគ្រោះដោយសារអំពើហិង្សាបង្កដោយដៃគូ | • ក្នុងករណីដែលអ្នកផ្តល់សេវាសុខភាព សង្ស័យថាមានករណីអំពើហិង្សា ប៉ុន្តែស្ត្រីមិនព្រមប្រាប់ ៖<br>• មិនត្រូវដាក់សម្ពាធលើគាត់ឡើយ ត្រូវទុកពេលឲ្យគាត់ |
| ស្នេហា *(ត)* | • ផ្តល់ព័ត៌មាន<br>- ទាក់ទងនឹងសេវាដែលមាន<br>- ទាក់ទងនឹងផលប៉ះពាល់នៃអំពើហិង្សាលើសុខភាពស្ត្រី និងកូនៗរបស់ពួកគាត់<br>• ផ្តល់ការចុះពិនិត្យជាបន្តបន្ទាប់<br>(សូមមើលសៀវភៅណែនាំគ្លីនិករបស់អង្គការ WHO, ទំព័រ ១២) |

| សេវាសំខាន់ៗ ៖ ២ ការគាំទ្រជួរមុខ | |
|---|---|
| នៅពេលផ្តល់ការគាំទ្រជួរមុខដល់ស្ត្រីដែលប្រឈមនឹងអំពើហិង្សា ត្រូវយកចិត្តទុកដាក់លើចំណុចទាំងនេះ ៖ (១) តម្រូវការសុខភាពផ្លូវចិត្ត/ផ្លូវអារម្មណ៍បន្ទាន់ (២) តម្រូវការសុខភាពផ្លូវកាយបន្ទាន់ (៣) តម្រូវការសុវត្ថិភាពជាបន្តបន្ទាប់ (៤) ការគាំទ្រជាបន្តបន្ទាប់ និងតម្រូវការសុខភាពផ្លូវចិត្ត។ ការគាំទ្រជួរមុខផ្តល់ការថែទាំ និងឆ្លើយតបទៅនឹងតម្រូវការសុខភាពផ្លូវចិត្ត ផ្លូវកាយ សុវត្ថិភាពរបស់ស្ត្រី និងការគាំទ្រ ដោយមិនបំពានលើភាពឯកជនរបស់ស្ត្រី។ ជារឿយៗ ការគាំទ្រជួរមុខគឺជាការថែទាំដ៏សំខាន់បំផុតដែលអាចត្រូវផ្តល់ ។ | |
| **សមាសធាតុស្នូល** | **គោលការណ៍ណែនាំ** |
| **២.១ ការថែទាំដែលផ្តោតលើស្ត្រី** | • ស្ត្រី ដែលរៀបរាប់ប្រាប់ពីរាល់ទម្រង់នៃអំពើហិង្សាបង្កដោយដៃគូស្នេហា (ឬសមាជិកគ្រួសារផ្សេងទៀត) ឬការបៀតបៀនផ្លូវភេទដោយជនបង្ក គួរទទួលបានការគាំទ្រភ្លាមៗ។<br>• យ៉ាងហោចណាស់ អ្នកផ្តល់សេវាសុខភាពគួរផ្តល់ការគាំទ្រជួរមុខនៅពេលដែលស្ត្រីទាំងនោះរៀបរាប់ប្រាប់ពីអំពើហិង្សា។ ការគាំទ្រជួរមុខមានបញ្ចូល ៖<br>  • ការមិនវិនិច្ឆ័យ តែត្រូវផ្តល់ការគាំទ្រ និងស្តាប់នូវអ្វីដែលស្ត្រីកំពុងរៀបរាប់ប្រាប់<br>  • ការផ្តល់ការថែទាំ និងការគាំទ្រដែលឆ្លើយតបទៅនឹងបញ្ហារបស់ស្ត្រី ប៉ុន្តែមិនត្រូវបំពានលើស្វ័យភាពរបស់ស្ត្រី<br>  • ការសួរពីរឿងរ៉ាវនៃអំពើហិង្សា ការស្តាប់យ៉ាងយកចិត្តទុកដាក់ ប៉ុន្តែមិនត្រូវបង្ខំឲ្យស្ត្រីនិយាយឡើយ (គួរមានការប្រុងប្រយ័ត្ននៅពេលពិភាក្សាពីប្រធានបទដែលប៉ះពាល់អារម្មណ៍ ក្នុងករណីមានអ្នកបកប្រែចូលរួម)<br>  • ការស្តាប់ដោយមិនបង្ខំឲ្យស្ត្រីឆ្លើយសំណួរ ឬរៀបរាប់ព័ត៌មាន<br>  • ការផ្តល់ព័ត៌មាន ការជួយឲ្យស្ត្រីទទួលបានព័ត៌មានពីធនធានមាន សេវាផ្លូវច្បាប់ និងសេវាផ្សេងទៀតដែលស្ត្រីគិតថាអាចមានប្រយោជន៍ និងជួយគាត់ឲ្យទទួលបានសេវា និងការគាំទ្រសង្គមផ្សេងទៀត<br>    - ការផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ស្តីពីយុទ្ធសាស្ត្រដោះស្រាយបញ្ហានៅពេលមានភាពតានតឹងខ្លាំង (ដោយហាមមិនឲ្យយកឯកសារ ឬបភាពទាំងនោះទៅផ្ទះ ប្រសិនបើដៃគូបង្កអំពើហិង្សាស្ថិតនៅទីនោះ) |

| | |
|---|---|
| | • ក្នុងករណីចាំបាច់ ត្រូវជួយស្ត្រីបង្កើនសុវត្ថិភាពផ្ទាល់ខ្លួន និងសុវត្ថិភាពកូនៗរបស់គាត់<br>• ការផ្តល់ភាពកក់ក្តៅ និងជំនួយដើម្បីបំបាត់ ឬកាត់បន្ថយអារម្មណ៍ភ័យខ្លាចរបស់គាត់<br>• ការផ្តល់ ឬកៀរគរការគាំទ្រក្នុងសង្គម (រួមមាន ការបញ្ជូនបន្ត)។<br>• អ្នកផ្តល់សេវាសុខភាពគួរធានាថា ៖<br>• ការផ្តល់ប្រឹក្សាត្រូវបានធ្វើឡើងនៅកន្លែងឯកជន<br>• មានការរក្សាការសម្ងាត់ តែត្រូវប្រាប់ស្ត្រីពីកម្រិតនៃការរក្សាការសម្ងាត់ (ឧទាហរណ៍ នៅពេលមានកាតព្វកិច្ចរាយការណ៍)។<br>• ប្រសិនបើអ្នកផ្តល់សេវាសុខភាពមិនអាចផ្តល់ការគាំទ្រជូរមុខបានទេ ពួកគេត្រូវប្រាកដថា មានអ្នកផ្សេងទៀតអាចធ្វើការងារនេះបានភ្លាមៗ (ក្នុងមណ្ឌលសុខភាពរបស់ខ្លួន ឬអ្នកផ្សេងទៀតដែលអាចជួយបាន)។<br>(គោលការណ៍ណែនាំរបស់អង្គការ WHO ៖ អនុសាសន៍លេខ ១) |
| **២.២ កាតព្វកិច្ចរាយការណ៍** | • អ្នកផ្តល់សេវាសុខភាព មិនគួររាយការណ៍ពីករណីអំពើហិង្សាលើស្ត្រីទៅនគរបាលឡើយ។<br>• អ្នកផ្តល់សេវាសុខភាពគួររាយការណ៍ពីអំពើហិង្សា ដែលបានកើតឡើងទៅកាន់អាជ្ញាធរមានសមត្ថកិច្ច (នគរបាល) ប្រសិនបើវាជាគោលបំណងរបស់ស្ត្រី ហើយស្ត្រីបាន យល់ពីសិទ្ធិរបស់គាត់។<br>• អ្នកផ្តល់សេវាសុខភាព ត្រូវរាយការណ៍ពីការរំលោភបំពានកុមារ និងសកម្មភាពគំរាមកំហែងអាយុជីវិតទៅអាជ្ញាធរពាក់ព័ន្ធ នៅពេលដែលលក្ខខណ្ឌច្បាប់តម្រូវឲ្យធ្វើដូច្នោះ។<br>(គោលការណ៍ណែនាំរបស់អង្គការ WHO ៖ អនុសាសន៍លេខ ៣៦ និង ៣៧) |

| សេវាសំខាន់ៗ ៖ ៣ ការថែទាំរបួស និងសេវាវេជ្ជសាស្ត្របន្ទាន់ | |
|---|---|
| ការពិនិត្យ និងការថែទាំសុខភាពរាងកាយ និងផ្លូវចិត្តគួរធ្វើឡើងរួមគ្នាប៉ុន្តែការបែងចែកសេវា ទាំងពីរនេះគឺ ដើម្បីផ្តល់ការណែនាំច្បាស់លាស់ពីស្តង់ដាអប្បបរមា សម្រាប់សេវានិមួយៗ។ | |
| **សមាសធាតុស្នូល** | **គោលការណ៍ណែនាំ** |
| **៣.១ រឿងរ៉ាវនៃអំពើហិង្សា និងការពិនិត្យ** | • ការកត់ត្រារឿងរ៉ាវនៃអំពើហិង្សា គួរអនុវត្តតាមនីតិវិធីវេជ្ជសាស្ត្រស្តង់ដា ប៉ុន្តែត្រូវចាំជានិច្ចថា ស្ត្រីដែលប្រឈមនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា ឬអំពើហិង្សាផ្លូវភេទ ច្រើនតែមានការប៉ះទង្គិចផ្លូវ |

| | |
|---|---|
| | ចិត្ត។ ដូច្នេះ ត្រូវពិនិត្យមើលឯកសារដែលគាត់មាន និងជៀសវាងការសួរសំណួរដែលគាត់បានឆ្លើយរួច។<br>• ត្រូវពន្យល់រៀបរាប់ និងទទួលបានការយល់ព្រមត្រឹមត្រូវសម្រាប់ចំណុចនីមួយៗខាងក្រោម ៖<br>  • ការធ្វើកោសល្យវិច័យ<br>  • ការព្យាបាល<br>  • ការប្រមូលភស្តុតាងកោសល្យវិច័យ<br>  • ការបង្ហាញព័ត៌មានដល់ភាគីទីបី ដូចជា នគរបាល និងតុលាការជាដើម។<br>• ប្រសិនបើស្ត្រីចង់បានភស្តុតាងដែលប្រមូលបាន ត្រូវស្នើ ឬបញ្ជូនករណីនេះទៅអ្នកផ្តល់សេវាសុខភាព ដែលទទួលបានការបណ្តុះបណ្តាលលើការងារនេះ។ សូមមើលសេវាសុខភាពសំខាន់ៗ ៖ ចំណុចទី ៦។<br>• រៀបចំការពិនិត្យរាងកាយឲ្យបានហ្មត់ចត់។ កត់ត្រាលទ្ធផល និងការសង្កេតឲ្យបានច្បាស់លាស់។ |
| | • នៅដំណាក់កាលនីមួយៗនៃការពិនិត្យ ត្រូវធានាឲ្យមានការទំនាក់ទំនង និងសុំការអនុញ្ញាតជាមុនសិន។<br>(សូមមើលសៀវភៅណែនាំគ្លីនិករបស់អង្គការ WHO ៖ ខ្លឹមសារលម្អិត ទំព័រ ៤០-៤៩) |
| **៣.២ ការព្យាបាលបន្ទាន់** | • ក្នុងករណីដែលស្ត្រីរងការគំរាមកំហែងដល់ជីវិត ឬជំងឺធ្ងន់ធ្ងរ ត្រូវបញ្ជូនស្ត្រីឲ្យទទួលបានការព្យាបាលបន្ទាន់ភ្លាមៗ។ |

| សេវាសំខាន់ៗ ៖ ៤ ការពិនិត្យការបៀតបៀនផ្លូវភេទ និងការថែទាំ | |
|---|---|
| អំពើហិង្សាផ្លូវភេទគឺជាបទពិសោធន៍គួរឲ្យភ័យខ្លាច ដែលអាចជះឥទ្ធិពលអវិជ្ជមានជាច្រើនលើ សុខភាពផ្លូវចិត្ត ផ្លូវកាយ ផ្លូវភេទ និងសុខភាពបន្តពូជរបស់ស្ត្រី និងត្រូវមានការថែទាំយ៉ាងយកចិត្តទុកដាក់ និងរយៈពេលវែង ជាពិសេសការថែទាំសុខភាពផ្លូវចិត្ត។ | |
| **សមាសធាតុស្នូល** | **គោលការណ៍ណែនាំ** |
| **៤.១ ការកត់ត្រារឿងរ៉ាវពេញលេញ** | • ត្រូវកត់ត្រារឿងរ៉ាវឲ្យបានពេញលេញ ដោយកត់ត្រារាល់ព្រឹត្តិការណ៍នានាដើម្បីកំណត់អន្តរាគមន៍សមស្រប និងរៀបចំការពិនិត្យ រាងកាយឲ្យបានគ្រប់ជ្រុងជ្រោយ (ពីក្បាលរហូតដល់ម្រាមជើង រួមទាំងសរីរាង្គបន្តពូជ)។ |

| | |
|---|---|
| | • រឿងរ៉ាវគួរបញ្ចូល ៖<br>• ពេលវេលានៃការកើតមានការបៀតបៀន និងប្រភេទនៃការបៀតបៀន<br>• ហានិភ័យនៃការមានផ្ទៃពោះ<br>• ហានិភ័យនៃការឆ្លងមេរោគអេដស៍ និងជំងឺកាមរោគផ្សេងទៀត<br>• ស្ថានភាពសុខភាពផ្លូវចិត្ត<br>(សូមមើលគោលការណ៍ណែនាំរបស់អង្គការ WHO ៖ អនុសាសន៍ទី ១១។ សម្រាប់ព័ត៌មានលម្អិត សូមមើលសៀវភៅណែនាំគ្លីនិករបស់អង្គការ WHO, ទំព័រ ៤០-៤៨)។ |
| **៤.២ មធ្យោបាយពន្យារកំណើតបន្ទាន់** | • ផ្តល់មធ្យោបាយពន្យារកំណើតបន្ទាន់ ដល់ជនរងគ្រោះដោយសារការបៀតបៀនផ្លូវភេទក្នុងអំឡុងពេល ៥ ថ្ងៃនៃការបៀតបៀន ហើយកាន់តែល្អជាងនេះទៅទៀតនោះ ត្រូវផ្តល់មធ្យោបាយពន្យារកំណើតឲ្យបានលឿនតាមដែលអាចធ្វើបាន បន្ទាប់ពីការបៀតបៀនដើម្បីបង្កើនប្រសិទ្ធភាព។<br>• ប្រសិនបើស្ត្រីបង្ហាញខ្លួន ក្រោយអំឡុងពេលត្រូវធ្វើការពន្យារកំណើតបន្ទាន់ (៥ ថ្ងៃ) នោះមធ្យោបាយពន្យារកំណើតបន្ទាន់នឹងមិន ទទួលបានជោគជ័យឡើយ ឬមានន័យថា ស្ត្រីនោះនឹងមានផ្ទៃពោះដោយសារការរំលោភសេពសន្ថវៈ។ ដូច្នេះ គាត់គួរទទួលបានការរំលូតកូនដោយសុវត្ថិភាព ដោយយោងតាមច្បាប់ជាតិ។<br>(សូមមើលគោលការណ៍ណែនាំរបស់អង្គការ WHO ៖ អនុសាសន៍លេខ ១២-១៤។ សម្រាប់ព័ត៌មានលម្អិត សូមមើលសៀវភៅណែនាំគ្លីនិករបស់អង្គការ WHO, ទំព័រ ៤៩-៥១)។ |
| **៤.៣ វិធីបង្ការមេរោគអេដស៍ក្រោយទទួលរងការរំលោភសេពសន្ថវៈ** | • ត្រូវផ្តល់វិធីបង្ការមេរោគអេដស៍ ក្រោយទទួលរងការរំលោភសេពសន្ថវៈ (PEP) ដល់ស្ត្រីក្នុងរយៈពេល ៧២ ម៉ោងនៃការបៀតបៀនផ្លូវភេទ។ ត្រូវធ្វើការសម្រេចចិត្តរួមគ្នាជាមួយជនរងគ្រោះដើម្បីកំណត់ថាតើវិធីបង្ការមេរោគអេដស៍ ក្រោយទទួលរងការរំលោភសេពសន្ថវៈសមស្រប ឬទេ និងអនុវត្តតាមគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីវិធីបង្ការរោគ។<br>(សូមមើលគោលការណ៍ណែនាំរបស់អង្គការ WHO ៖ អនុសាសន៍លេខ ១៥-១៨។ សម្រាប់ព័ត៌មានលម្អិត សូមមើលសៀវភៅណែនាំគ្លីនិករបស់អង្គការ WHO, ផ្នែក ២.៤, ទំព័រ ៥៥-៥៧)។ |

| | |
|---|---|
| **៤.៤ វិធីបង្ការជំងឺកាមរោគក្រោយទទួលរងការរំលោភសេពសន្ថវៈ** | • ស្ត្រីដែលជាជនរងគ្រោះដោយសារការបៀតបៀនផ្លូវភេទ គួរទទួលបានវិធីបង្ការរោគសម្រាប់ជំងឺកាមរោគទូទៅ និងថ្នាំបង្ការជំងឺថ្លើមប្រភេទ B ដោយយោងតាមគោលការណ៍ណែនាំថ្នាក់ជាតិ។<br>(សូមមើលគោលការណ៍ណែនាំរបស់អង្គការ WHO ៖ អនុសាសន៍លេខ ១៩-២០។ សម្រាប់ព័ត៌មានលម្អិត សូមមើលសៀវភៅណែនាំគ្លីនិករបស់អង្គការ WHO, ផ្នែក ២.៣, ទំព័រ ៥២-៥៤)។ |

| សេវាសំខាន់ៗ ៖ ៥ ការវាយតម្លៃសុខភាពផ្លូវចិត្ត និងការថែទាំ | |
|---|---|
| ស្ត្រីជាច្រើនដែលប្រឈមនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា ឬអំពើហិង្សាផ្លូវភេទ នឹងមានបញ្ហាសុខភាពផ្លូវចិត្ត ឬផ្លូវអារម្មណ៍ ហើយនៅពេលដែលអំពើហិង្សា ការបៀតបៀន ឬស្ថានភាពទាំងនេះកន្លងផុតទៅ បញ្ហាសុខភាពផ្លូវចិត្តទាំងនោះនឹងធូរស្រាលឡើងវិញ។ ស្ត្រីជាច្រើនបានធូរស្បើយឡើងវិញ។ អ្នកផ្តល់សេវាសុខភាពអាចផ្តល់ជំនួយ និងបច្ចេកទេសជាក់លាក់មួយចំនួនដល់ស្ត្រីទាំងនោះ ដើម្បីកាត់បន្ថយភាពតានតឹង និងឆាប់ជាសះស្បើយ។ យ៉ាងណាក៏ដោយ ស្ត្រីមួយចំនួននឹងទទួលរងបញ្ហាសុខភាពផ្លូវចិត្តកាន់តែធ្ងន់ធ្ងរជាងស្ត្រីផ្សេងទៀត។ ប្រការសំខាន់ ត្រូវចេះសង្កេតមើលស្ត្រីទាំងនេះ និងផ្តល់ការថែទាំដល់ពួកគាត់។ | |
| **សមាសធាតុស្នូល** | **គោលការណ៍ណែនាំ** |
| **៥.១ ការថែទាំសុខភាពផ្លូវចិត្តសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាបង្កដោយដៃគូស្នេហា** | • ស្ត្រីដែលជួបប្រទះអំពើហិង្សា គួរទទួលបានការវាយតម្លៃសុខភាពផ្លូវចិត្ត (រោគសញ្ញានៃភាពតានតឹងស្រួចស្រាវ ឬជំងឺបាក់ស្បាត (PTSD) ជំងឺធ្លាក់ទឹកចិត្ត ការប្រើប្រាស់គ្រឿងស្រវឹង និងថ្នាំញៀន ការធ្វើអត្តឃាត ឬការបង្កគ្រោះថ្នាក់លើខ្លួនឯង) និងទទួលបានការព្យាបាល ដោយប្រើប្រាស់ការណែនាំអន្តរាគមន៍ mhGAP ដែលផ្តោតលើពិធីសារវេជ្ជសាស្ត្រផ្អែកលើភស្តុតាងរបស់អង្គការ WHO សម្រាប់បញ្ហាសុខភាពផ្លូវចិត្ត។<br>• ការថែទាំសុខភាពផ្លូវចិត្ត គួរផ្តល់ឲ្យតាមរយៈអ្នកផ្តល់សេវាសុខភាពដែលមានការយល់ដឹងច្រើនពីអំពើហិង្សាលើស្ត្រី។ |
| **៥.២ ការគាំទ្រផ្លូវចិត្តជាមូលដ្ឋាន** | • បន្ទាប់ពីការបៀតបៀន ការគាំទ្រផ្លូវចិត្តជាមូលដ្ឋានអាចមានលក្ខណៈគ្រប់គ្រាន់សម្រាប់រយៈពេល ១ ទៅ ៣ ខែដំបូង ក្នុងពេលជាមួយគ្នានេះក៏ត្រូវមានការពិនិត្យតាមដានបញ្ហាសុខភាពផ្លូវចិត្តធ្ងន់ធ្ងរផ្សេងទៀតផងដែរ ដូចជា ៖<br>  • ជួយពង្រឹងវិធីសាស្ត្រដោះស្រាយបញ្ហាជាវិជ្ជមានរបស់ស្ត្រី<br>  • ស្វែងរកការគាំទ្រក្នុងសង្គម |

| | |
|---|---|
| | • បង្រៀន និងបង្ហាញពីលំហាត់កាត់បន្ថយភាពតានតឹង<br>• ផ្តល់ការពិនិត្យតាមដានជាប្រចាំ |
| **៥.៣ បញ្ហាសុខភាពផ្លូវចិត្តធ្ងន់ធ្ងរ** | • ធ្វើការវាយតម្លៃស្ថានភាពផ្លូវចិត្ត (ក្នុងពេលពិនិត្យរាងកាយ) ដើម្បីស្វែងរក ហានិភ័យភ្លាមៗ ឬការបង្កគ្រោះថ្នាក់លើខ្លួនឯង ឬការធ្វើអត្តឃាត និងជំងឺធ្លាក់ទឹកចិត្តមធ្យម-ធ្ងន់ធ្ងរ និងជំងឺបាក់ស្បាត<br>• ស្ត្រីដែលមានជំងឺធ្លាក់ទឹកចិត្ត និងជំងឺបាក់ស្បាតនៅតែទទួលបានការគាំទ្រជូរមុខ ដែលជួយពួកគេពង្រឹងការគាំទ្រក្នុងសង្គម រៀនគ្រប់គ្រងភាពតានតឹង និងការពិនិត្យតាមដានគាំទ្រប្រកបដោយការយល់ចិត្ត។ ប្រសិនបើមាន ត្រូវបញ្ជូនគាត់ទៅគ្រូពេទ្យព្យាបាលដែលទទួលបានការបណ្តុះបណ្តាល។<br>• ក្នុងករណីចាំបាច់ ត្រូវបញ្ជូនបន្តដើម្បី ទទួលបានការព្យាបាលផ្លូវចិត្តភ្លាមៗ ឬការព្យាបាលបញ្ហាពាក់ព័ន្ធនឹងការរៀនសូត្រ និង អាកប្បកិរិយា។<br>(សូមមើលគោលការណ៍ណែនាំរបស់អង្គការ WHO ៖ អនុសាសន៍លេខ ២៤-២៧។ សម្រាប់ព័ត៌មានលម្អិត សូមមើលសៀវភៅណែនាំគ្លីនិករបស់អង្គការ WHO, ទំព័រ ៦៧-៨៣)។ |

| សេវាសំខាន់ៗ ៖ ៦. ការចងក្រងឯកសារ (វេជ្ជសាស្ត្រ-ច្បាប់) |
|---|
| អ្នកផ្តល់សេវាសុខភាពមានកាតព្វកិច្ចវិជ្ជាជីវៈក្នុងការកត់ត្រាព័ត៌មានលម្អិត ស្តីពីការផ្តល់ប្រឹក្សាជាមួយអ្នកជំងឺ។ កំណត់សម្គាល់ត្រូវឆ្លុះបញ្ចាំងពីអ្វីដែលបានរៀបរាប់ជាពាក្យពេចន៍ដើម របស់អ្នកជំងឺ និងអ្វីដែលបានមើលឃើញ និងអនុវត្តដោយអ្នកផ្តល់សេវាសុខភាព។ ក្នុងករណី អំពើហិង្សា ការកត់ត្រាព័ត៌មានត្រឹមត្រូវ និងពេញលេញក្នុងអំឡុងពេលពិនិត្យ ពិតជាចាំបាច់ខ្លាំងណាស់ ដោយសារកំណត់ត្រាវេជ្ជសាស្ត្រអាចត្រូវបានយកមកប្រើប្រាស់ជាភស្តុតាងក្នុងតុលាការ។ ប្រសិនបើស្ត្រីព្រមព្រៀងឲ្យមានការពិនិត្យកោសល្យវិច័យ ត្រូវរកអ្នកពិនិត្យកោសល្យវិច័យផ្លូវការ ឬចុះបញ្ជី។<br>សម្រាប់ការណែនាំបន្ថែម សូមមើលគោលការណ៍ណែនាំស្តីពីការថែទាំផ្នែកវេជ្ជសាស្ត្រ-ច្បាប់សម្រាប់ជនរងគ្រោះ ដោយសារអំពើហិង្សាផ្លូវភេទ របស់អង្គការ WHO ឆ្នាំ ២០០៣។ គោលការណ៍ណែនាំទាំងនេះត្រូវបានបំពេញបន្ថែមដោយសេវាយុត្តិធម៌ និងការរក្សាសណ្តាប់ធ្នាប់សំខាន់ៗ-ចំណុចទី ៣ ៖ ការស៊ើបអង្កេតដែលមានលម្អិតក្នុងម៉ូឌុលស្តីពីយុត្តិធម៌ និងការរក្សាសណ្តាប់ធ្នាប់។ សូមមើលចំណុច ៣.៣ ៖ “ព័ត៌មានពាក់ព័ន្ធនិងភស្តុតាងត្រូវបានប្រមូលពីជនរងគ្រោះ និងសាក្សី” និងចំណុច ៣.៤ ៖ “ការស៊ើបអង្កេតគ្រប់ជ្រុងជ្រោយត្រូវបានធ្វើឡើង”។ |

| សមាសធាតុស្នូល | គោលការណ៍ណែនាំ |
| --- | --- |
| **៦.១ ការចងក្រងឯកសារគ្រប់ជ្រុងជ្រោយ និង ត្រឹមត្រូវ** | • ឯកសារផ្នែកវេជ្ជសាស្ត្រ កត់ត្រាបញ្ហាសុខភាព រោគវិនិច្ឆ័យ និងសញ្ញា រួមមានការរៀបរាប់ពីរបួសរបស់ស្ត្រី។<br>• ការសំខាន់ត្រូវកត់ត្រារាល់មូលហេតុ ឬមូលហេតុសង្ស័យនៃការរងរបួសទាំងនេះ ឬលក្ខខណ្ឌផ្សេងៗទៀត រួមទាំងអ្នកដែលធ្វើឲ្យស្ត្រីរងរបួស។<br>  • សុំការអនុញ្ញាតពីស្ត្រី ដើម្បីកត់ត្រាព័ត៌មាននេះទៅក្នុងកំណត់ត្រារបស់គាត់<br>  • ធ្វើតាមបំណងរបស់គាត់។ |
| **៦.២ ការប្រមូល និងការចងក្រងឯកសារស្តីពីវត្ថុវិភាគកោសល្យវិច័យ** | • នៅពេលដែលស្ត្រីយល់ព្រមឲ្យប្រមូលភស្តុតាងកោសល្យវិច័យ ត្រូវរក្សាភស្តុតាងទាំងអស់ ដោយមានបិទស្លាកសម្គាល់ច្បាស់លាស់។ |
| **៦.៣ ការផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ និងការចូលខ្លួនក្នុងតុលាការ** | • អ្នកផ្តល់សេវាសុខភាពត្រូវយល់ច្បាស់ពីប្រព័ន្ធច្បាប់ យ៉ាងហោចណាស់ត្រូវដឹងពីរបៀបសរសេរអំណះអំណាងឲ្យបានល្អ ចងក្រងឯកសារទាក់ទងនឹងការរងរបួសឲ្យបានពេញលេញ និងត្រឹមត្រូវ ធ្វើការអង្កេតផ្នែកគ្លីនិកឲ្យបានត្រឹមត្រូវ និងប្រមូលវត្ថុតាងផ្សេងៗដែលគួរឲ្យជឿជាក់ពីជនរងគ្រោះ នៅពេលដែលពួកគេសម្រេចជ្រើសរើសដំណោះស្រាយតាមផ្លូវច្បាប់។ |

# ជំពូក ៤ ៖ ឧបករណ៍ និងធនធាន

WHO និង UNHCR (២០១៥), ការគ្រប់គ្រងផ្នែកគ្លីនិកសម្រាប់ស្ថានភាពផ្លូវចិត្ត ជំងឺវិបល្លាសស្មារតី និងការប្រើប្រាស់គ្រឿងញៀនក្នុងស្ថានភាពមនុស្សធម៌បន្ទាន់ ៖ ការណែនាំស្តីពីអន្តរាគមន៍ផ្នែកមនុស្សធម៌ mhGAP (mhGAP-HIG) ទីក្រុងហ្សឺណែវ ប្រទេសស្វីស។

អង្គការ WHO, UNFPA និង UN Women (២០១៤) ៖ ការថែទាំសុខភាពសម្រាប់ស្ត្រីដែលប្រឈមនឹង អំពើហិង្សាបង្កដោយដៃគូស្នេហា ឬអំពើហិង្សាផ្លូវភេទ, សៀវភៅណែនាំគ្លីនិក ទីក្រុង ហ្សឺណែវ ប្រទេសស្វីស។

អង្គការសុខភាពពិភពលោក (២០១៣), ការឆ្លើយតបនឹងអំពើហិង្សាបង្កដោយដៃគូស្នេហា និងអំពើហិង្សាផ្លូវភេទលើស្ត្រី ៖ គោលការណ៍ណែនាំផ្នែកគ្លីនិក និងគោលនយោបាយរបស់អង្គការសុខភាពពិភពលោក, ទីក្រុងហ្សឺណែវ ប្រទេសស្វីស។

អង្គការសុខភាពពិភពលោក, មូលនិធិការប៉ះទង្គិចផ្លូវចិត្តដោយសារសង្គ្រាម និងអង្គការទស្សនពិភពលោក (២០១១), ការសង្គ្រោះបឋមផ្នែកចិត្តសាស្ត្រ ៖ ការណែនាំសម្រាប់អ្នកបម្រើការតាមមូលដ្ឋាន។

WHO (២០១០), ការណែនាំស្តីពីអន្តរាគមន៍ mhGAP សម្រាប់ជំងឺផ្លូវចិត្ត ជំងឺវិបល្លាសស្មារតី និងជំងឺបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀនក្នុងមជ្ឈដ្ឋានសុខាភិបាលគ្មានជំនាញ ទីក្រុងហ្សឺណែវ ប្រទេសស្វីស។

អង្គការ WHO និង ILO (២០០៧), គោលការណ៍ណែនាំរួមរបស់ WHO/ILO ស្តីពីវិធីបង្ការរោគក្រោយទទួលរងការរំលោភសេពសន្ថវៈ (PEP) ដើម្បីទប់ស្កាត់ការឆ្លងមេរោគអេដស៍ (២០០៧)។
អង្គការ WHO, UNFPA និង UNHCR (២០០៤), ការគ្រប់គ្រងគ្លីនិកសម្រាប់ជន រងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ។

អង្គការ WHO (២០០៣), គោលការណ៍ណែនាំស្តីពីការថែទាំផ្នែកវេជ្ជសាស្ត្រ-ច្បាប់សម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ។